# ការសំភាសន៍របស់លោកគ្រូ ហុង គា

**កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី　　ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ហុង គា**

## សង្ខេបរបស់លោកគ្រូ ហុង គា

លោកគ្រូ មានឈ្មោះថា ហុង គា អាយុ ៥៤ឆ្នាំ គាត់កើតនៅថ្ងៃទី៤ ខែ៧ ឆ្នាំ១៩៦៦ ទីកន្លែងកំណើត ភូមិព្រៃកបង្កង ឃុំព្រៃក តាកូវ ទីលំនៅបច្ចុប្បន្ន នៅហ្នឹងដែរ គាត់បានសិក្សាត្រឹមថ្នាក់ទី១០។ ឪពុកម្តាយរបស់គាត់ បានស្លាប់អស់ហើយ គាត់នៅតែម្នាក់ឯង សព្វថ្ងៃ ធ្វើលោកគ្រូ នៅបឋមសិក្សា វត្តស្វាយជ្រុំ គាត់នៅជាមួយបងប្អូនជីដូនមួយ។ កាលពីមុន គាត់បានរៀបការពីរដង ប៉ុន្តែបានលែងលះគ្នា ដោយសារប្រពន្ធរបស់គាត់ រស់នៅមិនចុះសំរុងជាមួយម្តាយគាត់។

កៈចាស ដំបូង ជម្រាបសួរ លោកគ្រូ!

ខៈបាទៗ

កៈចាស លោកគ្រូ! ថ្ងៃនេះ ខ្ញុំមាន ឪកាសមកសម្ភាស លោកគ្រូ ផ្ទាល់!

ខៈបាទ

កៈ នៅ អ្អឺ ខាង អ្អឺ ទីតាំងសាលា ម៉ង! អញ្ចឹងអ្អា លោកគ្រូ!

ខៈខាង សាលាស្វាយជ្រុំ បឋម។

កៈ ចាស ចាស! អញ្ចឹង អ្អឺ លោកគ្រូ អ្អឺ ថ្ងៃនេះ ថ្ងៃសម្ភាស គឺជាថ្ងៃទី២៦ ហើយខ្ញុំសម្ភាស មានឈ្មោះថា ហេង សុជីវី ហើយលោកគ្រូវិញ មានឈ្មោះអីដែរ?

ខៈខ្ញុំ ខ្ញុំឈ្មោះ ហុង គា

កៈចាស...

ខៈបាទ...

កៈលោកគ្រូ អ្ហឺ ឈ្មោះហ្នឹង ត្រូវមួយអត្តសញ្ញាណប័ណ្ណ និងទាំងនាមត្រកូល លោកគ្រូអ្ហេ ត្រូវនឹងនាមត្រកូលរបស់ លោកគ្រូអ្ហេ?

ខៈបាទ ត្រូវៗ ប៉ុននៅក្នុងអត្តសញ្ញាណប័ណ្ណ នៅហ្នឹង ទាំងអស់

កៈចាស

ខៈនៅ ទឹង(ទាំង) ប្រវត្តិ អីនៅនុង! បាទ។

កៈ អ្ហឹ ចាស លោកគ្រូ! សព្វថ្ងៃ អាយុម៉ានហើយ លោកគ្រូ?

ខៈអាយុ អ្ហឺ ៥៩ ហើយ។

កៈ លោកគ្រូ កើតនៅថ្ងៃទី ឆ្នាំណាដែរ លោកគ្រូ?

ខៈគឺទី ៩ ខែ៧! ៦៦!។

កៈ ចាស ចាស ហើយលោកគ្រូ ហើយអ្ហឺ ឆ្នាំខ្មែរ យើងវិញ លោកគ្រូ?

ខៈបាទ?

កៈ បើសិនជាឆ្នាំខ្មែរ យើងវិញ?

ខៈ ឆ្នាំខ្មែរយើង អ្ហឺ...

កៈដូចជា ឆ្នាំ ជូត ឆ្លូវ ខាល ថោះ អី? លោកគ្រូ ចាំអ្ហេ?

ខៈ អើយ... អត់បានចាំទេ

កៈ(សើច)

ខៈអត់ចាំ...

កៈចាស លោកគ្រូ! អញ្ចឹង អ្ហឺ កាលលោកគ្រូ កាលលោកគ្រូ! ជំនាន់មុន អ្ហឺលោកគ្រូ រៀនសូត្របាន កំរឹតណាដែរ?

ខះខ្ញុំ កាលខ្ញុំ រៀន! តាំងពីដើម សង្គមចាស់ ហ្នឹង! អ្ហឺ អ្ហឺ សង្គមរាស្ត្រ និយមហ្នឹង ថ្នាក់ទី... ហ៊ឺម? (រកនឹក) ថ្នាក់ទី១០ ថ្នាក់ទី១០ ត្រឹមតែថ្នាក់ទី ១០អ្ហេ! រៀនជាមួយគ្នា វ៉ែ! គ្នា ហ្នឹង! អ្ហឺ ត្រឹម អ្ហឺ បាន ថ្នាក់ទី១០ ពីៗ ដើមអ្ហា ត្រឹមថ្នាក់ទី១០ ហ្នឹង! សង្គ្រាម លន់ណុល អ្ហឺ វែសង្គម រាស្ត្រនិយម។

កះចាស អ្ហឺ ចុះអញ្ចឹង អ្ហឺ មូលហេតុអី បានលោកគ្រូ បាន អ្ហឺ បានជាលោកគ្រូ រៀនបានប៉ុនហ្នឹង សង្គ្រាម រឺក៏... ?

ខះសង្គ្រាម!

កះសង្គ្រាម អ្ហឺរៀន អត់ចប់ម៉ង លោកគ្រូ?

ខះបើចប់ត្រឹមហ្នឹង ម៉ង! ហើយសង្គ្រាម តាម៉ង!។

កះថ្នាក់ទី១០ ហ្នឹង! លោកគ្រូ រៀននៅសាលា ណាដែរ?

ខះរៀន អ្ហឺ នៅសាលា អ្ហឺ វត្តព្រៃកបង្កង ភូមិព្រៃក តាកូវ។

កះចាស

ខះបាទ

កះហើយ ចុះ កាលហ្នឹង លោកគ្រូ! រៀនពូកែ អ្ហេ លោកគ្រូ?

ខះរៀនមិនសូវប៉ាកែ(ពូកែ) ប៉ុនម៉ានទេ គ្រាន់តែបានមធ្យម

កះ(សើច)

ខះ(សើច) មធ្យម គ្រាន់តែរៀនបានមធ្យម។

កះហើយកាលរៀន អ្ហឺ កាលហ្នឹង លោកគ្រូ អ្ហឺ ដូចជាមាន រឿងអី ដែលលោកគ្រូចាំថា ដែលធ្វើ អោយលោកគ្រូ ចាំថា មានរឿងអីកើតឡើង មករហូត ដល់អាលូវអ្ហេ? ដូចជាគ្រូប្រាប់ ដំបូល ន្មាន មានដូចជាមានមិត្តភក្តិ ជិតស្និទ្ធ អីមួយ នៅក្នុងការសម័យហ្នឹង អ្ហឺ ការឃើញទិដ្ឋភាព ដែលលោកគ្រូចាំ រហូតមកដល់អាលូវហ្នឹងអ្ហា?

ខះកាលហ្នឹង វា អ្ហឺ បានតែត្រឹមថា ថ្នាក់ទី១០ហ្នឹង ពោលគឺថា រៀនបានត្រឹមមធ្យមហ្នឹង វា ខ្សោយចំណេះវិជ្ជាអ្ហា ខ្សោយអ្ហា ខ្សោយមុខវិជ្ជាណាមួយ ចំ អ្ហឺ គ្រូកាច គ្រូវ៉ៃ ខ្លាំងពេក គ្រូកាច អ្ហាណា

កៈចាស

ខៈធ្វើអោយខ្ញុំបាក់ ស្បាត យ៉ាងភ័យញ៉ាប់ញ័រ អ្ហឺ កាលហ្នឹង លោកគ្រូជំនាន់នុង កាចអ្ហា

កៈចាស

ខៈខ្ទប់ផាំង ក្តាខៀន! ត្រូវវា ដាក់! អាសំបកធុរេនអ្ហា ដាក់ទៅលើគុ អោយច្រាត់ ក្បាលជង្គង់ហ្នឹង! សង្កត់ថែមទៀត រួចមូលស្លឹកត្រចៀកទៀត អ្ហឺ ចង់ដាច់អ្ហាណា

កៈអូ លោកតា

ខៈណា! ខ្ញុំរៀននុង អ្ហា! ខ្ញុំស្រក់ទឹកភ្នែកអ្ហា នឹកឃើញ ជីវប្រវត្តិនុង ស្រក់ទឹកភ្នែក លោកគ្រូកាចអ្ហា លន់ៗ ណុល អ្ហា!។ ឪពុកថា ឪពុកម្តាយថា អ្ហឺ ធ្វើផង សុំតែឆ្អឹង ម៉ោ! បានហើយ រូជគ្រូ អ្ហឺ បានដៃ សង្គមនុង! បានដៃខ្លាំង លែងទាត់ផាំងតែ ម្តង! ទាត់ផាំង(គាត់ធ្វើសំលេង) លឺសូរ ប្រាវ អ្ហឺ ខ្ទប់ក្តាខៀន អ្ហឺ ជូនកាល អ្ហឺ បញ្ចូលដៃ អញ្ចឹង! អាបន្ទាត់ជ្រុងហ្នឹង ចឹងអ្ហា នៀកអ្ហា! វៃ ពីលើលឺផុស ថា! អ្ហឺ ឡើងស្រក់ទឹកភ្នែក ស្រក់ទឹកភ្នែក យំតាម៉ង(យំតែម្តង)។ ចឹងអ្ហា! បើមិន អញ្ចឹងទេ វៃ! បាតដៃ ខ្ញុំកាលហ្នឹង ខ្ញុំ! វៃបាតដៃ ខ្លាំងពេកអ្ហា បែកឈាមម៉ង! ឈាមអ្ហា វៃបន្ទាត់ វៃ! បន្ទាត់ជ្រុងអ្ហា មែនមូលទេ ថាបន្ទាត់ជ្រុងអ្ហា ថា! អ្ហឺ វែង ប្រវែងនេះអូ?

កៈចាស

ខៈវៃ ម៉ាទំហឹង! ម៉ាទំហឹង គាត់អ្ហា បានខ្ញុំ បានខ្ញុំបាក់ស្បាត

បងស្រីៈលែងចង់រៀន។

ខៈហ្នឹងហើយ លែងចង់រៀន គ្រូហ្នឹង! កាច កាចពេក ហ្នឹង! ជំនាន់ហ្នឹង លែងសិត(សុទ្ធ)តែគ្រូប្រុសៗ កាចអ្ហា កាលនុង! ប្អូនអាច...

កៈចាស

ខៈបើ អ្ហឺ អ្ហឺ រៀនៗ ពីជំនាន់ហ្នឹងអ្ហា ដឹង! ហ៊ឹម... ខ្លាចអ្ហាណា ខ្លាចគ្រូ គ្រាន់តែគ្រូ ឃើញគ្រូ ពីចំងាយតិច អង្គុយគុ ឡើង! ស្ងៀមស្ងាត់ ម៉ង! រួចៗ អត់មានការណែនាំ អប់រំ គរុកោសល្យ ដូចអាលូវហ្នឹង ទេ! អត់ទេ!

កៈចាស ប្រើ អំពើហឹង្សា!

ខ៖អាលូវ២ដង... បាទ! ប្រើអំពើហឹង្សា។

ក៖អ្ហឺ អញ្ចឹង! កាលហ្នឹង គាត់វៃ អ្ហឺ អញ្ចឹងហើយ អ្ហឺ លោកគ្រូ អ្ហឺ រៀនពូកែជាងមុន រឺក៏... អត់ទេ?

ខ៖រៀនអត់ ប៉ាកៃ(ពូកែ)ទេ!

ក៖ចាស រឺត តែខ្លាច

ខ៖ខ្លាចគេ បាទ!

ក៖ចាស

ខ៖ខ្លាច ខ្ញុំញ័រ ភ័យ អ្ហឺ អាដេញ អ្ហឺ ខ្លាច! គ្រូហ្នឹង ឡើងញ័រ ខ្លាចហ្នឹងអ្ហា។

ក៖ចាស ព្រោះអី លឺថា គ្រូវៃ! ដើម្បីអោយសិស្សខំប្រឹង អ្ហ លោកគ្រូ?

ខ៖ហ្នឹងហើយ ខំប្រឹង!

ក៖ដល់ពេល អ្ហឺ គ្រូវៃហើយ អត់! អត់ ដូចថា សិស្ស អ្ហឺ បែរជា... រៀន អ្ហឺ អត់ពូកែហើយ បែរជា អ្ហឺ បាក់ស្បាត ទៅតាមហ្នឹងដែរ!

ខ៖បាក់ស្បាត ហ្នឹង! ទៅតាមហ្នឹង ទៀតទៅ! វាខ្លាច បណ្ដោយហ្នឹង អូ។

ក៖(សើច)

ខ៖(សើច)

ក៖ចុះកាល នៅរៀន ?

ខ៖តាប៉ក់ៗ ប៉ុនៗហ្នឹងអ្ហា!

ក៖ខ្ទង់ អ្ហឺ តិចតួចអ្ហាណា លោកគ្រូ... ចាស!

ខ៖បាទ

ក៖ចាស ចាស អញ្ចឹង កាល អ្ហឺ នៅរៀន អ្ហឺ លោកគ្រូ! នៅរៀន លោកគ្រូ អ្ហឺ មានក្ដីស្រមៃ អ្ហឺ ដូចជា អ្ហឺ ធំឡើងចង់ធ្វើអី អត់ ?

ខ៖ខ្ញុំ!ថា... វាមិនដឹងថា អ្វី ម្ដាយមីងខ្ញុំ គាត់ទៅដាក់ដីម៉ង់ ហ្នឹង! ថា ចូលទៅ! ល័... អ្វី ល័បាន ជាប់ទៅ យើង! អ្វី រួចពី អា! ក... ៥! ហ្នឹង អ្វ...។ អាហ្នឹង! គេចាប់ អ្វី ធ្វើទ័ពអ្ហា តាមភូមិអ្ហា ធើទ័ព ទៅ អាខ្លះ គេទៅ អ្វី ជាន់មីន ដាច់ជើងទៅ ម្ដាយមីង! អ្វី ដាក់ដីម៉ង់ថា ជាប់ អ្វី រឺមិនជាប់អីដែរ ក៏! អស់ចិត្តដែរ អ្វី គាត់ប្រើទឹកលុយ អ្វី ធើម៉េច អ្វី បានជាប់ អ្វី ជាប់គ្រូហ្នឹងអ្ហា ដើម្បីអោយរួចផុត ពី រៀន អ្វី ក... ៥ហ្នឹងអ្ហា។ បញ្ជូនទៅ ម្ដងៗ ២០! ៣០នាក់ បញ្ជូន! ក្នុងភូមិហ្នឹងអ្ហា សិត(សុទ្ធ) ប្រុសៗ បញ្ជូនទៅ អ្វី ជូនកាល អ្វី អត់អី អត់អី អ្ហេ អ្វី សុខសប្បាយ ប៉ុនមិនអីអ្ហេ ប៉ុនមើលមិន ឃើញ ប្រើទៅ ដាច់ជើង ប៉ាដោយ(បណ្ដោយតាមហ្នឹង)។ អញ្ចឹង អ្វី បានខ្លាច! ហើយចឹង បញ្ហា អញ្ចឹង បានគាត់ដាក់បញ្ជូនទៅ កាលហ្នឹង ខ្ញុំរៀន តាំងពី... ៧៩! រ ហូត ដល់... ៨៥! ខ្ញុំជាប់ អ្វី... ថ្នាក់ទី៧! ទី៧អ្ហា ជំនាន់ អ្វី តេជោហ៊ុនសែន អ្វី ខ្ញុំរៀនថ្នាក់ទី៧ អ្ហា ខ្ញុំឡើងថ្នាក់ទី៧ ហ្នឹងទៅ អ្វី បាន អ្វី អស់ត្រឹមហ្នឹង បាន... អ្វី គាត់ដាក់ដី ម៉ង់! អោយធ្វើគ្រូហ្នឹងទៅ តទៅទៀត ដើម្បីអោយផុត រៀន! ក៥ ហ្នឹងអ្ហា ដាច់ជើង ហ្នឹងអ្ហា! ហ្នឹងអ្ហា... ជីវប្រវត្តិខ្ញុំ មានតែប៉ុហ្នឹងទេ (សើច)។

ក៖ចាស លោកគ្រូ! អញ្ចឹង អ្វី...

ខ៖បាទ

ក៖អញ្ចឹង លោកគ្រូ! កាលនៅកុមារភាព ដូចជា អ្វី លោកគ្រូ! អ្វី បានឃើញ អ្វី អ្វី ជីដូនជីតា លោកគ្រូ អ្វី គាត់ អ្វី មានជីវភាព បែបណា គាត់ប្រកបមុខរបរអីដែរ ជំនាន់ហ្នឹង?

ខ៖គាត់! កាលហ្នឹង មុខរបរ លក់ដូរ ចាប់ហួយ ដូច អ្វី ដូចអាលូវហ្នឹងអ្ហា ចាប់ហ៊ួយ ហ្នឹងអ្ហា! ដូច ថា ប៊ីចេង ខ្ទឹមស... អី ហើយ អ្វី ទឹកសាអ៊ី ទឹកអី! ចេះតែលក់ ទៅណា

ក៖ចាស

ខ៖ចំណេញ តិចតួច ទៅ! ដើម្បីទប់ទល់ អ្វី អ្វី ជីវភាពហ្នឹងទៅ លក់ទៅ ដល់អ្ហា ... នេះទៅ ដល់ អ្វី វា លក់ អ្វី គ្នាច្រើនពេកទៅ អ្វី វា អ្វី អត់សូវដាច់។ ដំ... អ្វី អត់សូវដាច់ គាត់ អ្វី វា អ្វី ឈប់លក់ អ្វី ហ្នឹង! ប៉ាដោយទៅ! ហ្នឹងហើយ (បណ្ដោយតាមហ្នឹង)។

ក៖ចាស

ខ៖បាទ ហ្នឹងហើយ! គ្នា អ្វី ច្រើនពេក ស្រុកកំណើត នៅណាដែរ អ្វី លោកគ្រូ

ក៖ចុះ ស្រុកកំណើត អ្វី នៅណាដែរ លោកគ្រូ?

ខ៖ស្រុកកាណើត(កំណើត)ខ្ញុំ! នៅ អ្វី ភូមិព្រៃកបង្កង ឃុំព្រៃក តាកូវ។

កះ នៅ ស្រុក អ្វី?

ខះនៅស្រុក ខ្សាច់កណ្តាល

កះចាស!

ខះបាទ ខេត្តកណ្តាល

កះ នៅទីនេះ ម៉ង ហ្នឹង?

ខះនៅ អ្វី អ្វី ផ្ទះ អឺ ផ្ទះចាស់ ហ្នឹង! តាំង អ្វី ពី ជីដូនជីតា ខ្ញុំចាស់ ម៉ង...។

កះអ្វី អញ្ចឹង! ផ្ទះចាស់ហ្នឹង តាំងពី អ្វី អ្វី ជំនាន់មុន អ្វី នៅតាំងពី ជីដូនជីតា លោកគ្រូ! នៅហ្នឹង?

ខះហ្នឹងហើយ...

កះនៅហ្នឹង! ហើយត... មកដល់... អ្វី ?

ខះនៅរហូតមកដល់ នៅហ្នឹងទៀត មកនៅហ្នឹង ទៀត!។

កះចុះផ្ទះហ្នឹង មានការប្រែប្រួលយ៉ាងណាដែរ លោកគ្រូ?

ខះផ្ទះហ្នឹង វា... ទ្រុបទ្រោម ដោយសារ កណ្តៀរ វា វាមានខ្លាំងពេក ! មុនដំបូង ទៅច្រូត នៅ បន្ទាយ ៧៩ ហ្នឹង! បាតដៃទទេហ្នឹង ទៅៗ ច្រូតកក់ យកមកត្រួង អ្វី ដើម្បី អ្វី ធ្វើជញ្ជាំងអ្នាណា ...

កះចាស

ខះបិតបាំងវា ទៅ! ព្រោះ ឡាហូត(រហូត) អ្វី ដល់ អ្វី ៨០ជាង ! កណ្តៀរ អ្វី ស៊ី អាកក់ ហ្នឹង! ទៀត ទៅ ដាក់! អ្វី កៀប ស្លឹកត្នោត! កៀបស្លឹកត្នោតអ្នា អ្វី អ្វី ដើម្បី អ្វី មកទប់ទល់ អ្នា ជញ្ជាំងហ្នឹង កុំ អោយវាធ្លុះធ្លាយពេក! (សើច) អ្វី មនុស្សណាល្អ មនុស្សណា អាក្រក់! យើងមើលមិនឃើញទេ អ្វី ទាំងយប់ប៉ាលប់(ព្រលប់) អ្នា កៀប អ្វី ប៉ាឃាំងអីទៅ! ហើយដេកទៅ ហ៊ឹម! ដល់ពេល អ្វី ចូល ៩០ជាង រួសចេញ អ្វី វាកណ្តៀរនុង ខ្លាំងពេក វាស៊ី ខ្លាំងពេក អ្វី អ្វី ស្លឹកត្នោត អូ អ្វី ខ្លាំងពេក ខ្លាំងពេក វែក្តា! វែក្តា ដាក់! ហើយនឹង ស័ង្កី ខ្លះ! ប៉ះពៅ ស័ង្កីខ្លះ ដល់ ដល់! អ្វី អ្វី ចូលឆ្នាំ ២០០០ អ្វី... ១៩ ហ្នឹងអ្នា

កះចាស

ខះកណ្ដៀរ ស៊ីខ្លាំងទៀត! ស៊ី អ្ហឺ ឡើងពុក ភុយ ទៅតាម៉ង!(ទៅតែម្ដង) អ្ហឺ បាន អ្ហឺ ដល់ទាល់តែនេះទៅ ប្អូនជីដូនមួយខ្ញុំហ្នឹង ផ្ដើម អ្ហឺ គំនិត ហ្នឹង! អោយជាង ហៅ អ្ហឺ រៀបឥដ្ឋ តាម៉ង! (តែម្ដង)

កះចាស

ខះរៀប ឥដ្ឋ! ប៉ាដោយទៅ (បណ្ដោយតាមហ្នឹង)។ វាស៊ី វាហួស ពេកអ្ហា ហើយ!(សើច)

កះចាស ចឹង អ្ហឺ សរុប ម៉ោ! ផ្ទះហ្នឹង ថ្ម... អ្ហេ?

ខះបាទ ជឿ អ្ហឺ ជឿផ្ទះថ្ម... ទៅ! ផ្ទះថ្ម ថា អ្ហឺ នៅផ្ទះទៀម តាដៃរ(ដដែរ) ហ្នឹងអ្ហា! ផ្ទះទៀមហ្នឹង តាដៃរ(ដដែរ)

កះម៉ូតអី ហ្នឹង?

ខះតែគ្រាន់ ថា... ផ្ទះ២ជាន់ រឺ ៣ជាន់ អ្ហេ! ដូចថា ដូចនេះអញ្ចឹង ដូច...

កះចាស

ខះអ្ហឺ ដូចឃ្លាំង ដាក់ អ្ហា ឡានចឹង! គៀនចឹង អ្ហឺ វៃប្រក់តាបូល(ប្រក់ដំបូល)... ស័ង្កី ស័ង្កុ អីទៅ! ធម្មតា ទៅ! អ្ហឺ អ្ហា បានផ្ទះ នៅ! ម៉ានៅ ទៅ!

កះអញ្ចឹង! ម៉ូតអី ទៅលោកគ្រូ?

ខះអត់ម៉ូត អីទេ

កះម៉ា ម៉ាច្រក អញ្ចឹង! អូ លោកគ្រូ?

ខះអ្ហឺ...

កះ ដី ទំហំ! វាម៉ាន អ្ហៅ?

ខះ ដី! មិនដឹង អ្ហឺ ទំហំ មិនដឹង អ្ហឺ ជាម៉ានអ្ហេ តាំងពីដូនតា ម៉ោ!

កះកេរ អ្ហឺ ម៉ោ! ដឹងថា ធំ!

ខះដឹងថា កេរ ម៉ោ! មិនដឹង បណ្ដោយ ទទឹង ហ្នឹង! ដឹង ប៉ុន្មានម៉ែត្រ... ខ្ញុំ អត់ដឹងដែរ ចេះតែរស់រស់ៗ នៅផ្ទះ ហ្នឹងទៅ!

ក៖ចាស

ខ៖បាទ

ក៖ចុះលោកគ្រូ មានបងប្អូន ម៉ាននាក់ លោកគ្រូ?

ខ៖ជីដូនមួយខ្ញុំ!

ក៖ចុះ បងប្អូនបង្កើត អូ លោកគ្រូ?

ខ៖បងប្អូន បង្កើត អ្ហឺ តែម្នាក់ខ្ញុំអ្ហែ

ក៖អូ អញ្ចឹង លោកគ្រូ កូនទោល អូ អញ្ចឹង អូ។

ខ៖បាទ កូនទោល ក៏នៅហ្នឹង កូនប្អូន ក៏នៅហ្នឹង (សើច) កូន៧ ក៏លើហ្នឹង ទាំងអស់!

ក៖ចាស ជាកូនទោល តែម្នាក់!

ខ៖ហ្នឹងហើយ កូនទោលម្នាក់ឯង ដូចរៀមច្បងគ្រួសារ ដូចលោកតា ស៊ិន ស៊ីសាមុត ! គាត់ច្រៀង អ្ហឺ អត់ខុសមែន (សើច)

ក៖ចុះ អ្ហឺ លោកគ្រូ អ្ហឺ មានអារម្មណ៍ យ៉ាងណាដែរ លោកគ្រូ?

ខ៖បាទ មិនដឹង ធ្វើម៉េច? អ្ហឺ បើម៉ោ ម្នាក់ឯង អញ្ចឹង! វា អ្ហឺ អត់មានប្អូន អត់មានអី ត! អ្ហឺ ទៅទៀត ចឹងអ្ហា រួចម៉ែខ្ញុំ ក៏គាត់ចែកឋាន ត! អ្ហឺ ទៅទៀត ទៅ! អ្ហឺ វាចប់ អស់! អាលីង តាម៉ង(តែម្តង) (សើច) អស់អាលីង អ្ហឺ ទៅ! រួច ក៏ អ្ហឺ ភរិយា! បែកបាក់គ្នា តាំង អ្ហឺ ពីជំនាន់ម៉ែខ្ញុំ នៅរស់ហ្នឹង គាត់ជឿ អ្ហឺ តាចៀកស្រោលពេក! បានបែកៗ បាក់! គ្នានុង អ្ហា! បានជាចំណាស់នេះ អ្ហៅ! រស់នៅតែលតោលម្នាក់ឯង ប្រៀបបាន អ្ហឺ ដូចចក ដូចចាផ្លោក(កំផ្លោក) អញ្ចឹង! នៅក្នុងទឹក នៅហ្នឹង អ្ហឺ ទៅ! ចេះ អ្ហឺ ទៅៗ មិនទាន់ប៉ះ ទើរ! ត្រង់អ្ហាណា មានថ្មី អ្ហា! ដូច អ្ហឺ ភរិយាថ្មី អ្ហា! ចេះតែលង់ៗ ទឹកហ្នឹងទៅ បានខ្ញុំចកកាផ្លោក(កំផ្លោក) (សើច)។

ក៖ចុះ អ្ហឺ លោកគ្រូ បែកពី អ្ហឺ ម្តាយ ដែលត្រូវជា អ្ហឺ ឪពុកម្តាយ អ្ហឺ អ្ហឺ លោកគ្រូ អ្ហា អ្ហឺ អ្ហា ឆ្នាំណា? យូរនៅ អ្ហឺ លោកគ្រូ?

ខ៖អូ អ្ហឺ អ្ហឺ ពីឆ្នាំ ២០១៨ ហ្នឹងអ្ហា ចែកឋាន គាត់ចែកឋាន អ្ហឺ ២០១៨ ហ្នឹងអ្ហា! ចែកឋានទៅ...

ក៖អូ អញ្ចឹង! លោកគ្រូ បានកេរម្ចល អ្ហា ចឹង?

ខះបាន ជីរូស ហ្នឹង! បានដី អ្ហឺ ជីដូន ជីតាហ្នឹង! រស់នៅបាន តទៅទៀត ទៅ!

កះចាស

ខះរស់នៅ នៅហ្នឹង តទៅទៀតទៅ! អ្ហឺ ជីដូនមួយ អ្ហឺ ផ្តើម អ្ហឺ គំនិតទៅ! បងប្អូន ជីដូនមួយហ្នឹង ៣! ៤! គ្រួសារ អ្ហា!។ អ្ហឺ គ្រួសារមួយហ្នឹង គេមានផ្តើមគំនិត គេរៀប រៀបអី ហ្នឹង! យើងរស់នៅ ថៃទាំហ្នឹង ទៅ... ដល់ អ្ហឺ យើងផុត អ្ហឺ ជីវិតទៅ បងប្អូនជីដូនមួយហ្នឹង ដែលសលហ្នឹង គេដឹង ទៅ ត... អ្ហឺ ទៅទៀត ទៅណា! អ្ហឺ យើងអស់ជីវិតទៅ! យើងត្រូវ អ្ហឺ ត្រឹមហ្នឹងហើយ យើងរស់ បាន ប៉ុន្មាន យើងរស់បាន ពីហ្នឹងទៅ...

កះចាស ចាស លោកគ្រូ ចាស!

ខះថា! ម៉ារស់ទៅ! រួច...

កះចាស ចាស លោកគ្រូ! ហើយដល់ពេលហ្នឹង ឪពុកម្តាយ អ្ហឺ លោកគ្រូ គាត់មានផ្តាំ លោកគ្រូ គាត់បានបន្សល់អីទុក អ្ហេ? អោយលោកគ្រូ?

ខះគាត់ អត់បាន អ្ហឺ ផ្តែផ្តាំ អីទេ! គាត់ អ្ហឺ គាត់ ដឹងខ្លួន អ្ហឺ គាត់ខុស! ត្រចៀកស្រាល ជឿ អ្ហឺ សំដី គេ! ធ្វើ អ្ហឺ បែកបាក់គ្រួសារ អាលីងហ្នឹង! គាត់ដឹងខ្លួនថា កំហុស! ខុស!

កះអូ អញ្ចឹង? អូ...

ខះអ្ហឺ គាត់អត់គិតវែង ឆ្ងាយអ្ហេ! នែ! ហើយ ខ្ញុំក៏ផ្តែផ្តាំ អ្ហឺ គាត់ដែរ អ្ហា ម៉ែហើយ ជាតិនេះ បើបែក បាក់គ្នាហើយ យើងធើបុណ្យ ធើទានទៅ។ ទៅភ្ជុំបិណ្ឌ ដាក់! នេះ! បណ្តោះកម្ម យើងបាច តែ អង្ករ អ្ហឺ ទៅ! ដើម្បីរំដោះកម្ម ជាតិហ្នឹង អោយអស់ អោយជាតិក្រោយ អោយជួបតែមនុស្សល្អ... អ្ហឺ ជា អ្ហឺ ម្តាយក្មេកស្រលាញ់កូនប៉ាសារ(កូនប្រសារ) ចេះស្រលាញ់ អ្ហឺ កូនបង្កើត! តាមគាត់ អ្ហឺ តែ២!៣! ម៉ាត់ហ្នឹងទេ មានតែធ្វើបុណ្យទានហ្នឹង ទេ! មានតែផ្លូវហ្នឹង អ្ហឺ មួយ! អ្ហឺ អ្ហឺ វា អ្ហា បែក បាក់គ្នា ទៅហើយ ប៉ាបាក(ពិបាក)រក ប្រពន្ធទៅចុះ! ចាំជាតិក្រោយ។ ខ្ញុំយាយ(និយាយ) ផ្តែ ផ្តាំគាត់ ហ្នឹងអ្ហា! ពេលគាត់ឈឺ ហ្នឹងអ្ហា។ អ្ហឺ ពេលគាត់ អ្ហឺ គាត់ អ្ហឺ អស់ជិវិត ទៅណា! ខ្ញុំផ្តែ ផ្តាំគាត់ មានតែប៉ុហ្នឹងទេ អត់មានបានស្អីទេ មានតែដីកេរហ្នឹង ទេ! កេរហ្នឹង ទេ! ដែលយើង មាន! ចេះតែទ្រាំ អ្ហឺ រស់នៅទៅ! ខ្ញុំយាយ(និយាយ)ប្រាប់គាត់ចឹងអ្ហា

កះចាស

ខះបាទ

ក៖ចាស ឪពុកម្ដាយ លោកគ្រូ ឈ្មោះអីដែរ?

ខ៖ឈ្មោះ ហុង ពិច។

ក៖ អ្ហឺ អ្ហឺ ម្ដាយ?

ខ៖ម្ដាយ! ឈ្មោះហុង ពិច

ក៖ចាស! ចុះ ឪពុកលោកគ្រូ?

ខ៖ឪពុកហ្នឹង អ្ហឺ ខ្ញុំលែង តាំងពី អ្ហឺ ក្នុងពោះម៉ែខ្ញុំម៉េស!

ក៖ហ៊ឹម!

ខ៖កើតម៉ោ អត់ឃើញ ម៉ង! ចុះអត់ប្រាប់

ក៖អត់ប្រាប់?

ខ៖ហើយអត់បន្សល់ រូបថត ទុកអោយមួយ ក៏មិនទុកទៀត គាត់ដុតចោល

ក៖អូ... អញ្ចឹង! អ្ហឺ មានន័យថា គាត់បែកបាក់គ្នា អ្ហឺ លែងលះគ្នាដែរ លោកគ្រូ?

ខ៖ហ្នឹងហើយ! លែងលះ តាំងពីខ្ញុំ នៅក្នុងពោះគាត់នុះ!

ក៖ចាស

ខ៖បាទ

ក៖អញ្ចឹង! រឿងរ៉ាវ តាំងពីឪពុកម្ដាយ លោកគ្រូ! លោកគ្រូ អត់ដឹងទាំងអស់?

រហូត ទាល់សព្វថ្ងៃ?

ខ៖អត់ដឹង ទាល់តែសព្វថ្ងៃ ហ្នឹង! ទៅ! តែ មុខគាត់យ៉ាងម៉េច? មុខឪពុកខ្ញុំ យ៉ាងម៉េច?

ក៖លោកគ្រូ អត់មានសួរ ជីដូនជីតា រឺក៏ចាស់ៗ មុន?

ខ៖ជីដូនជីតា...

ក៖ដែល អ្ហឺ ដែលគាត់បានស្គាល់ លោកឪពុក លោកគ្រូ អ្ហូ?

ខ៖នេះ... ពេល អ្ហឺ គាត់នៅរស់! ខ្ញុំសួរដែរ តែៗ គាត់ថា មិនដឹង គាត់ថាមិនដឹង គាត់ថាអញ្ចឹង! រួចរហូត ទាល់អ្ហា នេះទៅ រហូតដល់គាត់ ចែកឋានទៅ! ទៅអស់ អាលីងទៅ ម៉ង!(តែម្តង) ចាស់ៗ

ក៖ចាស...

ខ៖បាទ ពិបាកដែរ

ក៖ហើយ អ្ហឺ ចុះញ្ញាតិមិត្ត ជាអ្នកជិតខាងហ្នឹង គេដឹងអ្វេ ?គេថាម៉េចដែរ?

ខ៖ញ្ញាតិ? អ្នកជិតខាងហ្នឹង គេៗ ប្រាប់ថា ពុក អ្ហឺ អ្ហា អាទិត ឯងអ្ហា! មុខ ប្រហាក់ប្រហែល ដូច អាទិត ឯងចឹង! អ្ហឺ ... អ្ហឺ គាត់ អ្ហឺ អ្នកជិតខាង គេៗ អ្ហឺ ស្គាល់អ្ហា ប្រហាក់ប្រហែល ដូចអាទិត ឯង! អញ្ចឹង! រួច អ្ហឺ ដល់នេះទៅ អ្ហឺ ខ្ញុំក៏លែងសួរ អ្នកជិតខាងហ្នឹងទៅ ក៏... ថា! ទៅតាមចឹងទៅ ដំណើរ! គេឆាក ជីវិតហ្នឹង មិនដឹង អ្ហឺ ធើម៉េចទេ អ្ហឺ ...

បងស្រី៖គាត់ទៅណា វិញ លោកគ្រូ?

ខ៖យើងមិនអាច អ្ហឺ ទាញថយក្រោយម៉ោ វាមិនអាចទេ វាត្រូវតែទៅមុខ

ក៖ចាស

ខ៖ត្រូវតែ ទៅមុខ

ក៖ចាស អញ្ចឹង! លោកគ្រូ អ្ហឺ លោកគ្រូ អ្ហឺ នៅក្នុងចិត្ត លោកគ្រូ! អត់ចង់ដឹង ពី អ្ហឺ ឪពុកលោកគ្រូទៀតទេ អាល្ញូវ?

ខ៖ចង់ដឹងដែរ ក៏... ប៉ុន្តែ វា... អ្ហឺ វាអត់!

ក៖រកអត់បាន

ខ៖រក រក អត់បាន។

ក៖សួរគេ គេអត់ប្រាប់!

បងស្រី៖ ម៉ោ ម៉ោដល់អាល្ញូវ...

ក៖គេអត់ប្រាប់!

ខ៖គេ ឆ្លើយតាប៉ុហ្នឹង(តែប៉ុហ្នឹង) បាទ!

ក៖ចាស

ខ៖គេ ឆ្លើយ! តែប៉ុហ្នឹង

បងស្រី៖ម៉ោ ដល់អាលូវ ប្រហែលជា ស្លាប់បាត់ហើយ មើលទៅ។

ខ៖គេ អ្ហឺ ឆ្លើយតែប៉ុហ្នឹង គេ អ្ហឺ ឆ្លើយថា អ្ហឺ ជីវប្រវត្តិ អ្ហឺ គាត់ ដូច! ដូច មុខ អ្ហឺ មុខប្រហាក់ប្រហែល ដូចអាទិតឯង! ថា ខ្ញុំអញ្ជឹងអ្ហា !

ក៖ចាស

ខ៖រួច...

ក៖ចាស ចាស អញ្ចឹង! អ្ហឺ លោកគ្រូ អ្ហឺ សំរាប់ អ្ហឺ ប្រាថ្នា អ្ហឺ ចង់ដឹងលឺ អំពី ប្រវត្តិជិវិតរបស់ឪពុកបស់(របស់) លោកគ្រូ តាដែរ(ដដែរ)។

ខ៖បាទ

ក៖ចាស

ខ៖មិនដឹង បើ... ធើម៉េច បើ អ្ហឺ បើឆាក ជីវិត! វា អ្ហឺ ជួបតែប្រទះតា(តែ)ចឹង ទៅហើយ! មិនអាច...

ក៖ ចាស អ្ហឺ លោកគ្រូ អ្ហឺ មានដែល អ្ហឺ ប្រាថ្នាថា អ្ហឺ ថា ហ៊ឹម! អត់ទោស អោយគាត់ រឺក៏មាន អ្ហឺ ធើបុណ្យ អ្ហឺ អោយគាត់ រឺក៏មាន មានចិត្តមួយ អ្ហឺ ថា៖ អូ អ្ហឺ ចង់បាន តាណឹង(ដំណឹង) រឺ អី? ពី អ្ហឺ ឪពុក លោកគ្រូ អ្ហាណា? លោកគ្រូ អ្ហឺ មានចិត្តចឹងអឺណា?

ខ៖ធ្លាប់មានចិត្តចឹងដែរ ក៏ប៉ុន្តែ អ្ហឺ អ្ហឺ ដូចអត់ឃើញគាត់ ស្រមោលគាត់ អ្ហឺ ដូចអត់ឃើញគាត់ស្រមោល ចឹងអ្ហាណា មិនដឹងរស់ មិនដឹងស្លាប់ យើងអត់ដឹងដែរ ដល់... អ្ហឺ វាបាត់សូន្យឆឹង ត... អាលូវ រហូត ទាល់អាលូវហ្នឹងអ្ហា

ក៖ហ៊ឹម គាត់ធ្លាប់ ម៉ោលេង ម៉ោរកលោកគ្រូ អ្ហាអត់ លោកគ្រូ?

ខ៖អត់ អត់ម៉ោ លេងសោះ តាំងពីបែកបាក់ ពីម៉ែខ្ញុំទៅ ចប់ប៉ាដោយនុងអ្ហា អត់បាន...

ក៖ចុះ ចុះអញ្ជឹង

ខះទម្រាំតែដឹង...

កះមានន័យថា ពេលគាត់ការ ការនៅក្នុងស្រុកភូមិ ហ្នឹងដែរ?

ខះការ នៅអីស្រុក ភូមិហ្នឹងដែរ

កះចាស ! ចុះ អ្វី លោកគ្រូ អ្វី មានដូចជាមាន អ្វី ធ្លាប់ អ្វី ឪពុកម្ដាយ ដូចជា ធ្លាប់ការដោយស្របច្បាប់ រឺក៏ អ្វី ដូចតាម អ្វី ទំលៀមទំលាប់ឪពុកម្ដាយ រៀបចំទុកដាក់អោយ រឺក៏... ?

ខះហ្នឹងអ្ហា ម្ដាយ! រៀបចំ រៀបចំ ឪពុកគាត់អ្ហា រៀបចំ អ្ហា អ្វី ជូន អោយ ម្ដាយខ្ញុំហ្នឹង អោយម៉ោដណ្ដឹង ចូលដណ្ដឹង ម៉ែខ្ញុំហ្នឹងអ្ហា រួចដល់ អ្វី ដឹងរឿងស្អីទេ ខ្ញុំអត់ដឹងដែរ ដល់ហើយ កើតម៉ោ អត់ឃើញគាត់ប៉ាដោយ(បណ្ដោយតាមហ្នឹង)។ បើៗ បន្សល់ អ្វី នូវរូបថត អ្វី ម៉ាសន្លឹក អី ក៏! ក៏ខ្ញុំអស់ចិត្តដែរ អានេះ អត់សល់សោះ ម៉ង...

កះចាស ហ្នឹងហើយ អ្វី ពេល អ្វី លោកគ្រូផ្ទាល់អូ ម្ដាយរបស់របស់លោកគ្រូ ក៏គាត់អត់យកស្វាមី ទៀតដែរ?

ខះអត់យក ឡាហូត(រហូត) មកដល់ អាលូវ មានតែមួយ ចិញ្ចឹមតែម្នាក់ឯងហ្នឹង

កះចាស

ខះអ្វី...

កះអញ្ចឹង កេរតំណែល អ្វី ដូច អ្វី បាន បាន ពីឪពុក អ្វី អូ ដូចបានមកពី ម្ដាយ របស់លោកលោកគ្រូ ក៏បាន ជាផ្ទះ ដូចជាដី អ្វី មកដល់សព្វថ្ងៃហ្នឹងអ្ហា

ខះនៅ នៅ នៅហ្នឹងទៅ!

កះចាស ហើយចុះប្រវត្តិលោកគ្រូ វិញ! លោកគ្រូ អ្វី បានរៀបការ ដោយឪពុកម្ដាយ អ្នករៀបចំទុកដាក់អោយ រឺក៏ ស្រលាញ់គ្នា... ?

ខះហ្នឹងម្ដាយ គាត់ពេញចិត្តខ្លួនគាត់ អ្វី ពេលពេញចិត្តខ្លួនគាត់ តែ អ្វី គាត់ខុស ត្រង់អាកន្លែងគាត់ជឿ អ្វី សំដីគេ គេចាក់រុក ធ្វើអោយបែកបាក់គ្នា ក្នុងរង្វង់គ្រួសារហ្នឹងអ្ហា ដូចជា ត... អ្វី គ្នា ចឹងអ្ហា ដូចជាគាត់ ម៉ោ! ដល់កូនទៀត

កះហ៊ឹម!

ខ៖អញ្ចេក!

ក៖ចាស លោកគ្រូ!

ខ៖អញ្ចឹង បានថា ចឹងអ្ហា!

ក៖ចាស ចាស លោកគ្រូ អ្ហឺ ពាក្យដោយសារ អ្ហឺ ជឿ អ្ហា ម៉េច? ពាក្យ អ្ហឺ ដូចថា អ្ហឺ ពាក្យ ចាស់ៗ ភាគច្រើន តែងតែមាន ដូចថា អ្ហឺ គាត់! តែងតែ អ្ហឺ ឃើញ ពន្លឺថ្ងៃមុន អ្ហឺ អញ្ចឹង! អ្ហឺ គាត់ដឹងរឿង... ពីថ្ងៃមុន។ អញ្ចឹង! គាត់តែងតែ អ្ហឺ ជួយសំរបសំរួល អ្ហឺ កូនចៅហើយ...

ខ៖តែ... អ្នកជិតខាងហ្នឹង វាមានល្អ មាន! វាមាន អាក្រក់ដែរ អ្ហឺ ហ្នឹងហើយ អ្នកជិតខាង!។ ជូនកាលមនុស្ស មនុស្ស! អាក្រក់! គាត់ ចាក់រុកអ្ហា ចាក់រុក ថា! ព្រោះ ប្រពន្ធខ្ញុំ គ្រួសារខ្ញុំ អញ្ចេះ! ខិលខូច យកលុយកាក់ខ្ញុំ ទៅផ្ទះ រឺបង្ខូច រឺ អ្ហឺ បញ្ហា... ហ្នឹង! រឿងបញ្ហា ណាមួយ! អ្ហឺ វាចេះ តែ... អ្ហឺ លិចលឺ អ្ហា! លិចលឺ អ្ហា! អាអ្នកអាក្រក់ហ្នឹង ចេះតែតាម អ្ហឺ ឈ្នានីស ព្យាបាទ យើងអ្ហា! រួច អ្ហឺ ម្ដាយយើង ក៏ អ្ហឺ ជឿ តាមគេ ជឿតាមគេ បែកបាក់គ្នា អ្ហឺ តាមហ្នឹងទៅ!។ បើ... សិនជាគាត់ គោលជំហរ បស់(របស់)គាត់ បង្គោលរឹងមាំ កុំជឿគេ! គាត់ អ្ហឺ ត្រូវតាមដាន មើលសិន តើ ... អ្ហឺ អញ រៀបការ អ្ហឺ អោយកូនអញ អ្ហឺ កូនប្រសារហ្នឹង! តាម អ្ហឺ ជឿសំដីគេ គេ អ្ហឺ គេចាក់រុក អញ្ចឹង អ្ហឺ ទេ! កុំអោយតាមដានទេ គាត់ជឿគេ! ទាំងស្រុងទៅហើយ អ្ហឺ បានថា បែកបាក់គ្នា ចឹងទៅ (ម្ដាយគាត់ជឿលើពាក្យសំដីគេ ចាក់រុក ឈ្នានីស រវាងកូនប្រសារ ម្ដាយក្មេកឈ្លោះគ្នា បណ្ដាលអោយគាត់និងប្រពន្ធគាត់បែកបាក់គ្នា)។

ក៖ចាស ចាស

ខ៖បាទ! ឡាហូត(រហូត) ដល់គេ យកកូនចេញ ប៉ាដោយ(បណ្ដោយ)

ក៖អូ អូ... មានដល់ថ្នាក់ហ្នឹងទៀត អ្ហឺ លោកគ្រូ?

ខ៖ហ្នឹងហើយ ពន្លូតកូនចេញអ្ហា! គេសាមីខ្លួនហ្នឹងអ្ហា ស្រីហ្នឹងអ្ហា! ខ្ញុំ ខ្ញុំស្រក់ទឹកភ្នែក ម៉ង!។ សព្វថ្ងៃអ្ហា ខ្ញុំ ខ្ញុំនឹកឃើញ កាលណា ខ្ញុំស្រក់ទឹកភ្នែកតា ម៉ង! ឃើញកូនគេ កូនអី អ្ហឺ គេ អ្ហឺ ស្រលាញ់គ្នា អ្ហឺ ឪពុកស្រលាញ់ម្ដាយ កូន អ្ហឺ អីហ្នឹង! ខ្ញុំស្រក់ទឹកភ្នែក ខ្លួនឯង ម៉ង! ដែលមកជួបប្រទះ ដូចថាឆាក ជីវិត! ជួបប្រទះ ចឹងអ្ហា ថា! អ្ហឺ អាភ័ព្វ ខ្លួនឯង តាម៉ង(តែម្ដង)! ដឹងខ្លួនឯង អាភ័ព្វ ម៉ង!។ ពីជាតិមុន អ្ហាម៉េច? ធើបាបគេ អ្ហាម៉េច? អ្នក អ្ហឺ ជំពាក់បំណុលគេ អ្ហា ម៉េច? ទាញ អ្ហា ម៉េច? បានជួបជាតិនេះ ចឹង? អញ្ចឹង! ប៉ាដោយ(បណ្ដោយតាម)

ក៖ចាស

ខ៖បាទ ហ្នឹងហើយ បាន បាន ដូចថា មានតែ ធ្វើបុណ្យ ធើទាន ហ្នឹងទេ! មានតែផ្លូវហ្នឹងមួយអ្ហេ ដើម្បី អ្ហឺ អោយជួប មនុស្សល្អ ដឹងខុស ដឹងត្រូវ កុំជឿ អ្ហឺ គេហ្នឹងអ្ហា(សើច) តែជឿគេ បែកបាក់ទៀតហើយ(សើច)

ក៖ចាស

ខ៖បាទ

ក៖ចាស អញ្ចឹង! អ្ហឺ ដូចជាលោកគ្រូ គឺលោកគ្រូ ខ្លួនឯង តែម្ដងអ្ហាណា ដែលបានឆ្លងកាត់ជីវិតមកច្រើន ហើយបទពិសោធន៍ ជីវិត! ដែលលោកគ្រូ ចងចាំ! នូវរឿងដែល ជួបពិបាកជាងគេ អ្ហឺ មានអីគេខ្លះដែរ?

ខ៖អូ...

ក៖ចងចាំ មិនភ្លេច មកដល់ ដល់ អ្ហឺ អាលូវ?

ខ៖ដល់អាលូវ តាំងពី... ?

ក៖តាំងពី សម័យកាល! កាលជីដូន ជីតារបស់លោកគ្រូ បន្ទាប់ម៉ោ! អ្ហឺ បន្ទាប់ម៉ោ ឪពុកម្ដាយ បន្ទាប់ម៉ោ អ្ហឺ ម៉ោដល់ មកដល់ជំនាន់ហ្នឹង?

ខ៖ជំនាន់ហ្នឹង ខ្ញុំ អ្ហឺ ចេះតែគិតដែរ គិតថា៖ ខ្លួន! អាយុ កាន់តែច្រើនទៅ ច្រើនទៅ អ្ហេណ្ណ? ណ្ណ! វា អ្ហឺ ឈឺណ្ណ?

បងស្រី៖ ចាស អត់មានកូនចិញ្ចឹម?

ខ៖វា អ្ហឺ អត់មានកូន អូ! ហុច ទឹកក្ដៅ ទឹកត្រជាក់ ថ្នាំសង្កូវអី ហ្នឹង! វា វេទនា អ្ហឺ ខ្លួនឯង

បងស្រី៖ លោកគ្រូ អត់ អត់យក ប្រពន្ធមួយទៀត?

ខ៖អ្ហា ពេលចឹងទៅ អាពេលចុងក្រោយអឺណ្ណ អត់ទេ! ចង់យកមួយ ទៀតដែរ តែ! ប៉ុន្តែ អ្ហឺ ម្ដាយមីង នៅពេញហ្នឹង គាត់ដណ្ដឹង អ្ហឺ នៅឃុំ ស្វាយល្មៀត អឺណ្ណ! លើព្រែកតាមាក់ ហ្នឹង!

ក៖ចាស

ខ៖រួច យកម៉ោ កម្មពារ អ្ហឺ ទៀត បាទ! ម៉ែខ្ញុំ ធើបាន អ្ហឺ ពីមុន មីក្រោយនេះ ធ្វើបាប គាត់វិញ កម្មគ្នា សងគ្នា សងគ្នា ទៅទៀត អូ អស់អ្ហា

បងស្រី៖ កម្មមែន!

ខ៖បាទ កម្មគ្នា ត! គ្នា តាម៉ង(តែម្តង) អ្ហឺ អ្ហឺ ចឹង អ្ហឹ បាន អ្ហា ថា! ដូចៗ ធម៌ព្រះ លោកទេសន៍ អត់ខុសទេ ធ្វើអំពើល្អ បានល្អ ធ្វើអំពើអាក្រក់ អ្ហឹ បានអាក្រក់។ អញ្ចឹង! អ្ហឺ បានអ្ហាថា ខ្ញុំ អ្ហឺ នៅតែលតោល ប៉ាដោយ(បណ្តោយតាមហ្នឹង) ប៉ាដោយហ្នឹង! អ្ហឺ សព្វថ្ងៃ នៅតែលតោលរហូត ទាល់អាលូវ ហ្នឹង!។ សព្វថ្ងៃហ្នឹង អ្ហឺ ទៅហូបបាយ ផ្ទះម្តាយមីង ទៀតអ្ហា! សព្វថ្ងៃ ហ្នឹង! វាមានស្អីទៀត អស់អាលឹងហើយ! ម្តាយចែកឋាន ប្រពន្ធកូន ក៏អស់អាលឹង មានស្អីទៀត ដូចថា ដូចអញ្ចេក! ត្រីក៏រួច ទន្សាយ ក៏រួច!

កៈចាស ដូចលោកគ្រូ មានដែរ អ្ហឺ អ្ហឺ ដូចជា អ្ហឺ គិតថា ចង់ អ្ហឺ បានភរិយាក្រោយទៀត ដែលស្រលាញ់គ្នា ដោយចិត្តនិងចិត្ត រឺក៏ ឪពុកម្តាយ ជាអ្នករៀបចំអោយ រឺក៏របស់ខ្លួនឯង ដោយចិត្តនឹងចិត្ត មានអ្ហេ លោកគ្រូ?

ខ៖វា អ្ហឺ...

កៈដូចថា អ្ហឺ ស្រលាញ់គ្នា ដូចជា និស្ស័យអ្ហា ផលបុណ្យ វាសាង ផលបុណ្យមួយគ្នា ចឹងអ្ហា ធ្វើអោយ អាចៗរៀបចំគ្រួសារមួយ ដោយ ដោយចិត្តខ្លួនឯង ដោយចិត្តខ្លួនឯង?

ខៈចង់ណាស់ ក៏ប៉ុន្តែ អ្ហឺ វាអស់ គាត់ទៅហើយ ខ្ញុំ គ្មាន កប់យោបល់ ប៉ាដោយទៅ(បណ្តោយតាមហ្នឹងទៅ) វា អ្ហឺ បង្គោលរឹងមាំមួយ នៅជំហរ ហ្នឹង! ដ៏អស់ហ្នឹង បង្គោលហ្នឹង ម្តាយមីង ក៏គ្នា គាត់អស់ចាណាយ(ចំណាយ)លុយ អស់ច្រើន អស់រៀបការអោយ ប៉ុហ្នឹងហើយ អ្ហឺ គាត់ជួយថា៖ អរគុណ ដែលគាត់ទៅចុះ អ្ហឺ បានថា មីងនៅពេញហ្នឹង (គាត់ចង់បានប្រពន្ធ ចង់កសាងជីវិតថ្មី តែខ្លាចចិត្តម្តាយមីង ដែលគាត់ធ្លាប់រៀបការអោយគាត់ ចំណាយអស់ច្រើនហើយ ដូចនេះ គាត់លែងចង់បាន)។ អ្ហឺ... ម្តាយមីងខ្ញុំ និងម៉ែខ្ញុំហ្នឹង អ្ហឺ បងប្អូនបង្កើត! អ្ហឺ ហ្នឹងហើយ ម្តាយធំ អ្ហា! បាទ! រួចដល់ អ្ហា គាត់ ឃើញ អ្ហឺ កម្មពារ វា អ្ហឺ សង! សងចុះ សងឡើងចឹង! គាត់អស់លុយគាត់ច្រើនដែរ គាត់ គាត់កប់! យោបល់ ត្រឹមហ្នឹងទៅ(សើច)(សំលេង! គាត់ដេញសត្វកាង្ហាន់)(កៈនិយាយក្រៅសាច់រឿង កាង្ហាន់ បស់ លោក)

កៈចាស ដល់ពេល អ្ហឺ ចឹង! លោកគ្រូ អ្ហឺ ទុកនៅក្នុងចិត្ត ថាអញ្ចេក! មានគោលការ ផែនការអីទៀត អ្ហឺ សំរាប់ អនាគតរបស់លោកគ្រូ ខ្លួនឯងផ្ទាល់អ្ហា ការងារ... អ្ហឺ ទាំងផែនការ ជីវិត និង ហិរញ្ញវត្ថុ សំរាប់ អ្ហឺ តទៅមុខទៀតដែរ លោកគ្រូ អ្ហឺ ចង់ប្រាថ្នា ខ្លួនឯងអ្ហា មានអីទៀតលោកគ្រូ?

ខ៖វា អ្ហ៊ី អញ្ចឹង! បានថា វា វា អ្ហ៊ី កប់យោបល់ ត្រឹមហ្នឹងទៅ អ្ហ៊ី វា មិនអាចទៅ មុខរួច វា អ្ហ៊ី កប់យោបល់ ត្រឹមហ្នឹងទៅ! ម្ដាយមីងខ្ញុំ ក៏ អ្ហ៊ី វា អ្ហ៊ី កប់យោបល់ ត្រឹមហ្នឹងទៅ អ្ហ៊ី ស៊ីសង អ្ហ៊ី ម្ដាយមីង អ្ហ៊ី អាឡៃ្យង(អាស្រ័យ) អុំខ្ញុំ ហ្នឹងហើយ! គាត់ដឹកនាំ អោយ អ្ហ៊ី មានអនាគត ទៅមុខអ្ហា រួច ដល់ដែលយើង អ្ហ៊ី ឃើញយើង កម្មពារ អ្ហ៊ី អញ្ចឹង! គាត់អស់ សឹង! អស់សឹង រៀបការ រៀបចំ អោយយើង អនាគត យើងទៅមុខអ្ហា ដូចរបៀបថា អ្ហ៊ី អស់សង្ឃឹម ម៉ងអ្ហា ណា!

ក៖ចាស

ខ៖អ្ហ៊ី យើងឃើញកម្មពារ ម៉ង! អ្ហ៊ី ជាតិហ្នឹង អោយឃើញ ទាន់ហាន់ អញ្ចឹង! គាត់ៗ ទាល់តំរិះ បណ្ដោយហ្នឹងអ្ហា គាត់អស់ច្រើនដែរហ្នឹង មិនធម្មតាទេ មែន មែនតិចទេ លោកអើយ! ហ្នឹងហើយ ច្រើនណាស់ ការ នុះ!

ក៖កាលហ្នឹង ជំនាន់ហ្នឹង ម៉ាន? លោកគ្រូ?

ខ៖បាទ?ដឹង ម៉ានលានទេ ខ្ញុំអត់ដឹងដែរ ហ្នឹង!កាលនុង ម៉ែខ្ញុំ រៀបចំហ្នឹង តែគាត់គិតថា អ្ហ៊ី អោយរៀបចំហ្នឹង អ្ហ៊ី ម្ដាយមីងខ្ញុំហ្នឹង អ្ហ៊ី អោយរៀបចំហ្នឹង គឺ អ្ហ៊ី ដើម្បី អ្ហ៊ី អោយ អ្ហ៊ី ចាស់ ព្រឹត្តិចាស់ព្រេង ទៅ! ដើម្បី អ្ហ៊ី ថៃ ថៃគ្នា ទៅវិញ ទៅម៉ោ អ្ហាណា។ ចឹង! បាន អ្ហ៊ី ថា! អ្ហ៊ី រៀបចំ អ្ហ៊ី អ្ហ៊ី បានអ្ហាថា! ប្ដីប្រពន្ធគ្នា អ្ហ៊ី អោយមើលថៃទាំ គ្នា អ្ហ៊ី ឈឺស្កាត់(ឈឺថ្កាត់)អីទៅ រួច អ្ហ៊ី អ្ហា ឃើញចឹង! ក៏កប់យោបល់ដែរ គាត់អត់ គាត់ក៏អត់ អត់! អ្ហ៊ី ទាល់ច្រកដែរ គាត់ក៏អត់ រៀបចំទៀតទេ! អ្ហ៊ី គាត់ក៏បញ្ចប់ ត្រឹមហ្នឹង ប៉ាដោយហ្នឹង ហើយគាត់ ក៏អស់លុយគាត់ច្រើនដែរហ្នឹង អ្ហា...

ក៖ចាស ចាស សរសើរចិត្តរបស់ អ្ហ៊ី របស់ឪពុកមា

ខ៖បាទ ហ្នឹង

ក៖ របស់ខាង អ្ហ៊ី លោកគ្រូ...

ខ៖ហ្នឹង ហ្នឹងហើយ

ក៖ ហើយអ្ហ៊ី សព្វថ្ងៃ គាត់នៅ អ្ហ៊ី ភ្នំពេញ ហើយក៏ នៅនេះ?

ខ៖គាត់នៅ នៅពេញ អូ?

ក៖ចុះ បើគាត់វិញ អ្ហ៊ី គាត់ អ្ហ៊ី មានមុខរបរ ការងារអី ប្រកប អ្ហ៊ី ខាងអី ដែរ?

ខ៖មុខរបរគាត់ គាត់លក់នំ លក់អីហ្នឹងអ្ហា!

ក៖ចាស

ខ៖លក់នំ លក់អី នៅ អ្ហឺ ពេញហ្នឹង អ្ហា

ក៖ឥវ៉ាន់ ចាប់ហួយ!

ខ៖ អ្ហឺ ជីវភាពអី អ្ហឺ ចិញ្ចឹម អ្ហឺ ជីវិតកូនគាត់ ចៅគាត់ ក្មួយគាត់ មានដែរ តា អ្ហឺ គាត់។

ក៖ចាស ចុះលោកគ្រូវិញ លោកគ្រូ! មានមុខរបរជាអីដែរ លោកគ្រូ?

ខ៖ខ្ញុំហ្នឹង ហ្នឹង មុខរបរហ្នឹង ធ្វើគ្រូ បង្រៀនហ្នឹង។

ក៖បានត្រឹម ថ្នាក់ទីម៉ាន លោកគ្រូ?ចាស!

ខ៖ ខ្ញុំ អ្ហឺ នៅធ្វើការ ប៉ារ៉ូ ហ្នឹង! ដល់ អ្ហឺ ដល់ខ្ញុំ អ្ហឺ មានជំងឺ អ្ហឺ ៣!៤ដង អ្ហ អ្ហ...។ ខ្ញុំ អ្ហឺ ណាមួយ អ្ហឺ បាក់ស្បាត អ្ហឺ ជំនាន់ អាពត ផង! អ្ហឺ ណាមួយ មានជំងឺ អ្ហឺ ទៀត! ខ្ញុំបាក់ស្បាត អ្ហា! អ្ហឺ ជំនាន់អាពត អ្ហា។

ក៖ យ៉ាងម៉េចទៅ លោកគ្រូ? កាលហ្នឹង ?

ខ៖ជំនាន់ អាពត នុង! ជីក អ្ហឺ គំរាម គំហែងខ្ញុំ មុខវិជ្ជា អ្ហឺ គ្រប់ផ្នែក ទាំងអស់! វាសួរ កំរឹត វប្បធមិ បស់ខ្ញុំ អ្ហឺ ខ្ញុំ អ្ហឺ ថា៖ មិត្តបងអើយ! ខ្ញុំអត់ចេះទេ... ខ្ញុំរៀន អ្ហឺ ថ្នាក់ ស្រះ អ ស្រះ អា! ចេះតែពីរហ្នឹង ស្រះ អ ស្រះ អា!។ វា អ្ហឺ សួរ ជីវប្រវត្តិ យើងអ្ហាណា ហើយ អ្ហឺ ខ្ញុំ អ្ហឺ អត់ចេះ អក្សរ អ្ហឺ ទេ! អ្ហឺ អ្ហឺ សង្គ្រាម វៃគ្នាពេក ខ្ញុំ អ្ហឺ រត់! ខ្ញុំអត់បាន អ្ហឺ រៀនទេ ហើយវា អ្ហឺ ចង់ដឹង អ្ហឺ យក! វា អត់ជឿ វា អ្ហឺ វាយក អា អ្ហា... កាសែត មកអោយ អ្ហឺ យើងមើល! អក្សរ អ្ហា! ខ្ញុំ អ្ហឺ អត់ចេះទេ ចេះតែ មើលតែរូប បញ្ច្រាស់ចុះ បញ្ច្រាស់ឡើង អ្ហឺ ខ្ញុំ អត់ចេះមើល ទេ! វា ប៉អ្ហឺ ពិសោធន៍ខ្ញុំ អ្ហឺ ថា៖ អោយ អ្ហឺ តែដឹង អ្ហឺ កំរឹត វប្បធមិ អ្ហឺ យើងដឹង! វា យកយើង អ្ហឺ ទៅរៀនសូត្រ ហើយ! វាយកយើង អ្ហឺ ទៅ វៃចោលអ្ហា អ្ហឺ វា អ្ហឺ គំរាមគំហែង... .! អ្ហឺ នៅគ្រប់រូបភាព មានគ្រប់យ៉ាង ម៉េចក៏ដោយ! ខ្ញុំ អ្ហឺ អត់ចេះទេ បងអ្ហើយ បងឯង វៃខ្ញុំ យ៉ាងម៉េចក៏ដោយ! ខ្ញុំ អ្ហឺ ចេះតែស្រះ អ ស្រះ អា ហ្នឹង! អ្ហឺ រៀន អ្ហឺ ពីដើម! អ្ហឺ បានតែប៉ុហ្នឹង ទេ! រួច អ្ហឺ ដល់ អ្ហា នេះទៅ បាន! អ្ហឺ វា អ្ហឺ ស្អែកឡើង វាអោយយើងចូលរៀន ជាមួយ អ្ហឺ វា! ចូលរៀនមួយវា! ចូលរៀនជាមួយវា អ្ហឺ ធម្មតា ស្រះ អ យើងទាញ! ពីលើ ចុះមកក្រោម អ្ហាណា! រួច អ្ហឺ ខ្ញុំមិនទាញ ពីលើចុះ ម៉ោក្រោមទេ! ខ្ញុំ អ្ហឺ ទាញបញ្ច្រាស់! ខ្ញុំទាញបញ្ច្រាស់ ...

ក៖ចាស

ខះពីក្រោម!

កះពីក្រោម ឡើងលើ!

ខះបញ្រ្ចាស ឡើងទៅវិញ អ្ហឹ បញ្រ្ចាស់ទៅវិញ នែ! (សំលេងប៉ុលពតនិយាយ)អ្ហា អ្ហា មែនទេ! មិត្តឯង មិនមែន! ទាញពីក្រោម ឡើងទៅលើទេ! ទាញពីលើចុះ ម៉ោក្រោម។ ប៉ុនខ្ញុំ ធើ លូង់ អ្ហាណា! ខ្ញុំដឹង ថា! អាហ្នឹង អ្ហឹ វា យកទៅយើង អ្ហឹ រៀនសូត្រហើយ ចំណេះវប្បធម៌កំរឹត អីហ្នឹង!គេយកទៅវៃ ចោលហើយ ខ្ញុំដឹង ដូចកាលផ្លូវឡាងឹត(ឯងឹត) ប្រាប់! យើងចឹងអ្ហាណា ផ្លូវអាងឹត គេមកប្រាប់យើង អ្ហា ថាះ កុំធើ អ្ហឹ ចេះ ធើលូង់ ប្រសើរជាង នៅរស់ ដល់ អ្ហឹ នេះទៅ! ខ្ញុំទាញ អ្ហឹ ពីក្រោម ឡើងទៅលើវិញ ទាញបញ្រ្ចាស់នៀក! វា មើលដៃ យើងអ្ហា! ហើយវាចាប់ដៃយើង អ្ហឹ អោយទាញ ពីលើចុម៉ោ ក្រោមអីណ្ហេះ ស្រះ អ...។ គ្រប់រូបភាព ទាំងអស់ អ្ហឹ ណា! កុំអោយវា ចាប់ថ្នាក់បាន! រួចស្រះិ! អ្ហឹ ធម្មតា យើងស្រះិ យើងទាញ អ្ហឹ អញ្ចេក! អ្ហាណា ហ៊ឹម! អញ្ចេក អីណ្ហារួចខ្ញុំ ទាញ! អ្ហឹ អញ្ចេក ម៉ោ! បញ្រ្ចាស់ ទៅវិញ(សើច)។

កះ(សើច) ចាស! ដើម្បី អោយ...

ខះបាទ ថា អ្ហឹ បញ្រ្ចាស់ ទាំងអស់! ដៃខ្ញុំ អ្ហឹ ទាញ! អញ្រ្ចាស់ ទៅវិញ! អាស្រះុ អ្ហឹ វា អ្ហឹ ចេញម៉ោ! អ្ហា អញ្ចេក! អ្ហាណា អ្ហឹ! ទាញ ខ្វេ... ម៉ោបញ្រ្ចាស់ អញ្ចេក!

កះដើម្បី កុំអោយ គេដឹង!

ខះហ្នឹង! កុំងអោយ យើងដឹង អ្ហឹ វប្បធម៌យើង អ្ហា! ផ្លូវអាងឹត(ព្រលឹងមកប្រាប់គាត់) យើងធើ! ធើលូង់! កុំធើ អ្ហឹ ចេះ!

កះចុះ អ្ហឹ កាលហ្នឹង គេមាន អ្ហឹ ធើបាប លោកគ្រូ ម៉េចដែរ ?

ខះវា គំរាមគំហែង! វា អ្ហឹ អស់រូប គ្រប់រូបភាពហើយ ម៉េច? អ្ហឹ បាន អោយយើងចូលរៀន អោយយើង ចូលរៀន ស្រះ អ ស្រះ អា។ ហើយដល់ម៉ោង អ្ហឹ វា អោយយើងទូល... អញគោ ចាក់ស្រែ... ប៉ុន្មានតោន ប៉ុន្មានហិចតា វា! អ្ហា វាប្រើ អោយប្រើ អោយវាបោសសំរាម ពីក្បាលភូមិម៉ោ អ្ហឹ ចុងភូមិ! បើឃើញ អ្ហឹ យើងបោស ស្អែកហ្នឹង បានៗ ឃើញ បានបាយហូប របប អ្ហឹ វា! បើយើងមិនបោសទេ ស្អែកហ្នឹង! ត្រូវដាច់ពោះ យើងហូបទៀតបាយ អញ្ចឹង អ្ហាទៀត អ្ហា!។ បោស! តាំងពីយប់ រហូត អ្ហឹ ម៉ោង ១២ យប់អ្ហា! ពាក់កណ្ដាលអាធ្រាត្រ អ្ហឹ ធើម៉េច អ្ហឹ ពីក្បាលភូមិ ដល់ចុងភូមិ អោយបោស អ្ហឹ អោយហើយ កុំអោយភ្លឺ អ្ហឹ ទាន់! វេទនាណាស់ អ្ហឹ តាំងពីជំនាន់អាពត ទៅហើយ... វេទនា អ្ហឹ ណាស់! ហើយមិនបាន តែប៉ុណ្ណោះ ធើអោយយើង ដល់

ទៅ! ដល់ពេញវ័យ រូបរាង ជាកំលាំង នាំយើងហើយ អោយយើងទៅ ជីកព្រែក!។ ជីកព្រែក ពីយប់ ម៉ោង២ រហូតទាល់ អ្អឺ ម៉ោង ១២ថ្ងៃ ត្រង់! បានអោយយើងឈប់ ហើយ អ្អឺ អោយយើងសំរាកតិចតួចចឹងទៅ ម៉ោង២ថ្ងៃ ឡាហូត(រហូត) ទាល់ អ្អឺ ម៉ោង៨យប់ តើសួរថា កូនឯង មានកំលាំងអីណា អ្អឺ ទៀត។ អីណា! អ្អឺ បបរតែម៉ាបោយ(ប្រៀបធៀបអោយបបរគាត់តិច ញាំមិនគ្រប់) អ្ហេ! បបរអ្ហា អោយតែ អ្អឺ ២!៣គ្រាប់ទេ ខ្ញុំ! អ្អឺ ចាប់ផ្តើម អ្អឺ ស្គមទៅៗ ហើយ ស្គមទៅហើយ រួចតាកូន(ត្រកូន)អ្ហា! ម៉ោ ទាំងស្លែរ ទាំងឫស ទាំងល្ពើង ម៉ោ... ទៀត! អូនអ្អើយ វេទនាណាស់ អារឿង អ្អឺ ជីវប្រវត្តិលោកគ្រូផ្ទាល់ គឺ អ្អឺ ថា វេទនាណាស់។ របបហ្នឹង អ្អឺ វា អ្អឺ ព្រៃផ្សៃ អីណាស់! ហើយបើយើងឈឺអ្ហា វាថា យើងឈឺ អ្អឺ ធើពុតស្បាយ(ពុតទន្សាយ) អញ្ចេក អ្អឺ វាដល់ថ្នាក់ហ្នឹងអ្ហា។ ស្គមទៅៗ អ្អឺ ថា៖ សួរ..អ្អឺ ទៅ អ្អឺ ឪពុកម្តាយ កូនឯង អ្អឺ សួរគាត់ទៅ អ្អឺ ចាស់ៗហ្នឹង។

ក៖ចាស

ខ៖ជីវប្រវត្តិ គឺថា លោកគ្រូប្រាប់ទៅ អ្អឺ ទឹកភ្នែក អ្ហា! ជីវប្រវត្តិ វាហ្នឹងអ្ហា ទឹកភ្នែក។ ជីកព្រែកជំរៅ អ្អឺ ៥! ៥ម៉ែត្រទៅក្រោម បាត! អ្អឺ ក្រោម! ៥ម៉ែត្រ វាថែមកន្លះម៉ែត្រ អោយយើងជិះ អ្អឺ ទៀត ជីក អ្អឺ ទៀត! ជីក អ្អឺ ចបកាប់ ហើយនិង បង្គី ហើយនិងដងរែក ហ្នឹង! នៅតែកញ្ចង់ក..យើងទេអោបនឹងដើមទ្រូង។ ជួងវៃ សព្វថ្ងៃហ្នឹងអ្ហា! លោកគ្រូ គ្រាន់តែលឺ សូរជួង ហ្នឹងអ្ហាស្រក់ទឹកភ្នែកខ្លួនឯង ជីវប្រវត្តិជំនាន់អាពតហ្នឹង ស្រក់ទឹកភ្នែក ម៉ង! ស្រក់ទឹកភ្នែក ឆ្អែត! តាម៉ង(តែម្តង)

ក៖អញ្ចឹងអូ? លោកគ្រូ

ខ៖ហ្នឹងហើយ វាធើបាប យើង! គ្រប់រូបភាព

ក៖ជួងហ្នឹង?

ខ៖លឺ អ្អឺ លឺសូរ តែលោកគ្រូ អ្អឺ ទៅវៃជួង ហ្នឹង! អ្អឺ ស្រក់ទឹកភ្នែក លោកគ្រូ! លោកគ្រូ អ្អឺ ស្រក់ទឹកភ្នែក រួចស្រេចហើយ រាល់ថ្ងៃហ្នឹងអ្ហា រហូតទាល់រាល់ថ្ងៃ អ្ហា..

ក៖ហើយចុះ គេយកជួងហ្នឹង ទៅ! ធ្វើអី លោកគ្រូ?

ខ៖ជូរហ្នឹង វៃ អ្អឺ ជាសញ្ញា អោយប្រមូល អ្អឺ អោយ អ្អឺ ទៅជីកព្រែក កំលាំង អ្អឺ ទៅជីកព្រែក។ កាលណាអ្អឺ យើងមិនជីកព្រែក វា អ្អឺ វៃ អ្អឺ សិត(សុទ្ធ)តែកាំភ្លើងអ្ហា វៃផូស ផូស ដូចឆ្កែ ដូចឆ្មា ចឹង!

ក៖(សំលេងភ្ញាក់ផ្អើល)លោកគ្រូ មានដែល គេវៃ អ្ហា អត់?

ខះលោកគ្រូ អ្ហឹ កាន់តែបង្គី ហើយនិងដងចប! អាដេញ អ្ហឹ ចបកាប់ហ្នឹង នៅតា(នៅតែ) អោប នឹងដើមទ្រូង អ្ហែ!

កះចាស ខ្លាច!

ខះលឺ សូរតែវា វែជួងហើយ ហៅទៀត ហៅ អ្ហឹ ទៅជីកព្រៃកទៀត អ្ហាណ្ណ! រួចគ្នីគ្នា លោកគ្រូ ប៉ុន្មាននាក់ ៩!១០!នាក់ (ពួកគាត់បាននិយាយ) ហ៊ឹម... អញ អញស៊ី ផ្លែៗ ស្លែង អោយងាប់ ផ្លែ ស្លែង អ្ហឹ ទទួល វាជ្រុះ! ម៉ោ វាទុំ អូ! ខ្ញុំថា អ្ហឹថា ៖ អ្ហែ... ហ្វែង ងាប់តែ ហ្វែង ទៅ ហើយនៃ ក៏ងាប់ ដែរ វាៗ វានុង វាៗ វេទនា អ្ហឹ ដល់ថ្នាក់ហ្នឹង អ្ហា! វាឆ្អែតចិត្ត អ្ហាថា វា អ្ហឹ វេទនា អ្ហា! អ្ហឹ ហៅថាសំ រាក អ្ហា! ហើយទឹក ក៏អត់មានមុជ វា! គឺ អត់មានទឹកមុជសោះ គូក ខោអាវ អត់មានទឹកមុជ អត់ គូស ខោអាវទៀត។ កាលហ្នឹង នៅស្រុកស្រែ ជីកស្រុកស្រែ រួចខោអាវ ខ្មៅ! ខោខ្មៅ ហ្នឹង ឡើង កាកអំបិល រួចធុំ ឆ្អិះ ធុំស្អុយ ម្នាក់ៗ អ្ហើ... អូយ វេទនា អ្ហាណាស់។ ហ្នឹងអ្ហា វាប្រើខ្ញុំជីកហ្នឹង ជីក អ្ហឹ ដើម្បីយក អ្ហឹ ទីតាំងហ្នឹង! យក អ្ហឹ យើង ហ្នឹង! យកទៅ អ្ហឹ សំលាប់ចោលហ្នឹង ធ្វើការអោយវា ហ្នឹង! សំរាប់ ទម្លាក់! សម្លាប់ចោលហ្នឹងអ្ហា ក្នុងអណ្ដៅ ព្រៃកហ្នឹងម៉ង។

កះ(សំលងភ្ញាក់ផ្អើល)រួចលោកគ្រូ មួយទៀត! លោកគ្រូ ចំរើន អ្ហឹ មួយទៀត ថាគ្រូហ្នឹង! គាត់ជី ក ម៉ោ! នៀក ម៉ោ អ្ហឹ គាត់ជីក ម៉ោ អង្គភាពស្វាយជ្រុំ នៅហ្នឹងអ្ហា! ហើយរួចខ្ញុំ អង្គភាពក្នុងព្រៃក ភូមិព្រៃកតាកូវ ជីកជិតគ្នាហ្នឹងអ្ហា អត់ហ៊ានយាយ(និយាយ) គ្មានមាត់ឆ្លងឆ្លើយគ្នា ទេ!

បងស្រីះ តែយាយ(និយាយ)ទៅ?

ខះ ព្រោះឈ្លប់ អ្ហឹ ដើរ តែតាមពីក្រោយខ្ញុំ ទេ! ពីក្រោយខ្នងយើង ហ្នឹង! វាត្រួតពិនិត្យមើល ដល់! ពេល អ្ហឹ ៧៩! បែក ខ្ញុំសួរថា លោកគ្រូ! អ្ហឹ ចុះព្រៃកហ្នឹង យ៉ាងម៉េច? អ្ហឹ... លោកគ្រូ អ្ហើយ!លំ! បាត់ហើយ អ្ហឹ ស្រលះ សាធូប អមោទនា ទៅ! អ្ហឹ អាលំ បាត់ទៅ យកយើង! គំរោងយកយើង មកផែនការ សំលាប់ចោលក្នុងព្រៃកហ្នឹង។ ប្រមូលៗ ប្រជាពលរដ្ឋទាំងអស់ យកម៉ោ! ម៉ោ សម្លាប់ចោល នៅហ្នឹងម៉ង! រួចប៉ុណ្ណេះហើយ អោយយើងហ្នឹង ជីក! អោយវា វាប្រើអោយ យើង ជីក! ហើយ វាធ្វើបាបយើងគ្រប់រូបភាពហើយ ហើយអោយយើង ងាប់ទៅក្នុងអណ្ដៅព្រៃកហ្នឹង ណា! អូនឯង គិតទៅមើល?(សំលេងភ្ញាក់ផ្អើល) របបព្រៃផ្សៃ អ្ហាណា!

បងស្រីះចាស

ខះបាន អ្ហឹ វាអាលំ អាលាយ...

ក៖ចាស

ខ៖ចឹងហើយ ជីវប្រវត្តិរបស់លោកគ្រូ ម៉ាតាណាក់ ពីរ តាណាក់! វេទនាណាស់ មិនស្រួលសុខទេ។

ក៖លោកគ្រូ ពេលហ្នឹង មានឃើញគេយក មនុស្សទៅសម្លាប់ចោល នៅផ្ទាល់ភ្នែក លោកគ្រូអ្ហា អត់?

ខ៖អត់ទេ វាសម្លាប់ អ្ហឺ ឃើញគ្រប់ អ្ហឺ រូបភាពហើយ អ្ហឺ អាផ្ទះមួយហ្នឹង កាលពីដើមហ្នឹង ហៅតាកែហ្នឹងអ្ហា ហៅតាកែ អ្ហឺ ឡ... ឥដ្ឋ។ ហើយអត់អោយយើងដើរ នៅជិតក្បែរ នៅជិតហ្នឹង អ្ហឺទេ! កងឈ្លប់វា អ្ហា! វា យក អ្ហឺ អ្នកចេះដឹង សម្លាប់ចោល អ្ហឺ នៅហ្នឹងអ្ហា (សំលេងលោកគ្រូធ្វើតម្រាប់តាម)ផូស! អួយ ផូស! អួយ... ងាប់បាត់...

បងស្រី៖ប៉ុន្មាននាក់ទៅ?

ខ៖ អ្ហឺ មិនដឹងប៉ុន្មាននាក់ទេ អត់អោយយើងដឹង អ្ហេ! អ្ហឺ ចំនួនម៉ាននាក់ អ្ហេ យើងអត់ដឹងអ្ហេហើយ អ្ហឺ យកទៅរៀន សូត្រ! ត្រង់ហ្នឹង។ រួចសព្វថ្ងៃ ដល់ពេល អ្ហឺ ៧៩ហ្នឹង! លង លង! កន្លែងហ្នឹង ម៉ង! សម្លាប់ចោល...

ក៖លង! លោកគ្រូឃើញ អ្ហេ?

ខ៖អត់ទេ អ្នកស្រុក អ្ហឺ នៅក្បែរហ្នឹង លង! លង! នឹង អា អា នៅ អា បន្ទាយកប់ ហ្នឹង!

ក៖មិនលង អា! អ្នកគេសម្លាប់នោះ លោកគ្រូ?

ខ៖រួច អ្ហឺ នៅក្នុង អា អ្ហឺ អ្ហឺ បន្ទាយ អ្ហឺ ឃុំឃាំង ហ្នឹង! លង...។ ដល់នេះទៅ បាន! អ្នកម្ចាស់ថ្មីហ្នឹង! អ្ហឺ ភូមិឃុំ ហ្នឹង! ប្រគល់ អ្ហឺ អោយភូមិឃុំ ហ្នឹង! វៃ អ្ហឺ ទាំង អ្ហា ឃ្លាំង! ហ្នឹងចោល វៃ អ្ហឺ អា... ឃុំឃាំងហ្នឹង ចោល! អស់!។ វៃចោលអោយអស់ រួចដីហ្នឹង កន្លែង ដែលវាផ្ទះ វាកប់ហ្នឹង ចាក់សាប តាម៉ង ចាក់សាប បំបាត់!បំបាត់ អ្ហឺ កន្លែង! កន្លែងទី... តាំង អ្ហឺ វា! វាសម្លាប់ចោលហ្នឹង អស់! កប់ហ្នឹង អូ!។

ក៖អាក្រក់!

ខ៖ហ្នឹងអ្ហា អាលូវ! សាប អាលាប អ្ហា! មិនបានអ្ហេ ណា មិនបាន ទេ! បាទ។

កះលោកគ្រូ ចុះលោកគ្រូ នៅ អ្ហឺ ជំនាន់ហ្នឹង អ្ហឺ មានដែលបន់ ថា! អោយឆាប់ដាច់ភ្លាមៗអ្ហេ លោកគ្រូ?

ខះគេ អ្ហឺ កាលហ្នឹង អ្ហឺ លោកគ្រូ អ្ហឺ អត់មានដឹងថា មិនដឹងថា អ្ហឺ គេបន់ យ៉ាងម៉េច? រួចពី ឈ្លប អ្ហឺ វា ដើរតាម ពីក្រោយ អញ្ចឹងអ្ហា! យាយ(និយាយ) យ៉ាងម៉េច? ឈ្លប យ៉ាងម៉េច ?ហើយវា ឃើញ តែថ្លែង កាភ្លើង(កាំភ្លើង) លីកាភ្លើង(កាំភ្លើង)។ ហើយ អ្ហឺ កាលហ្នឹង អ្ហា មិនមែន មនុស្ស ធំៗ អ្ហេ សិត(សុទ្ធ) អ្ហឺ ក្មេងៗ! ក្មេងៗ! អ្ហឺ អាយុ ជាង២០ តិច! ជាង៣០ លីកាភ្លើង(កាំភ្លើង)

បងស្រីះអូ លោកគ្រូ ភ័យ!

ខះបាទ អ្ហឺ ជំនាន់នុង អ្ហឺ មិនដែរ អ្ហឺ ធ្លាប់ហាក់លោតទេ បើហាក់លោត អ្ហឺ បានដឹង អ្ហឺ ថាះ ដឹងថា វេទនា អ្ហឺ បាបាក(ពិបាក) យ៉ាងណាអ្ហា? ហើយ អត់អោយយើង ហូបឆ្អែត អ្ហឺ ទៀត។ យើងអឺ ណ្ណោះ ក្រពះយើង អ្ហឺ ណ្ណោះ! ថា! ឃ្លាន... បន្ទះអីនៃ(សើច) អ្ហឺ អ្ហឺ វាត់ឆៅ ឆៅ! ស្អី ក៏វាត់ដែរ ឃ្លាន! រួចខ្នុរ ធុរេន អីៗ! អត់អោយ យើងប៉េះស៊ី អាហេវ! នុះ អ្ហឺ ទេ! អ្ហឺ អោយទុំ ជ្រុះ ចោល! អ្ហឺ អត់អោ យយើងហូបទេ ទើ! តែយើងលួច ហើយបើលួចហ្នឹង! ២នាក់ហ្នឹង! ២នាក់ហ្នឹង សហាការគ្នា ត្រូវ ជើងគ្នា អាហ្នឹង អ្ហឺ លួច! កុំអោយ អ្ហឺ វាឃើញ!...

បងស្រីះ តែឃើញ វាយក ទៅសម្លាប់ហើយ។

ខះហ៊ឹម តែឃើញ! អ្ហឺ វាយកយើង ទៅរៀនសូត្រដែរ រៀនសូត្រ អ្ហឺ វាសម្លាប់ចោលអ្ហា! ថា អ្ហឺ ចោទយើង ថាះ មិនចោល អ្ហឺ បោះបង់ចោល អ្ហឺ ពីសង្គមចាស់ អ្ហេ! យើងនៅតែលួច ផ្លែឈើ ហើយវាចោទយើង អ្ហឺ ឃ្មាំង! វាចោទយើងអ្ហា រួចម៉េចហើយ ខ្នុរ ធុរេន អ្ហា ខ្នុរ ទឹកដោះគោ អី ហ្នឹង! អ្ហឺ ទុំ! ជ្រុះចោល អ្ហេ អត់អោយយើងប៉េះ អាហ្នឹង! ទេ។

កះចាស ចាស

ខះហ្នឹងអ្ហា រួចកាលហ្នឹង ខ្ញុំ! ពីរនាក់ហ្នឹង សហាការគ្នា ត្រូវជើងគ្នាអ្ហា ទម្លក់ដៃគ្នា ហើយ! មិន កើតជាមួយគ្នា ទេ! អាយុ ខុសគ្នា អ្ហឺ ធ្វើម៉េច អោយងាប់! ងាប់! ជាមួយគ្នា ស្បថស្បែ ទម្លក់ដៃនុ ងអ្ហា! រួចសុភាសិត មាន! អ្ហឺ តែមួយឃ្លា ទេ! លាក់ការខ្ពស់ រស់! បានយូរ... សុភាសិត មានតែ៣ ឃ្លា ហ្នឹង ទេ! សុភាសិត មានតែ៣ឃ្លា ហ្នឹងទេ! លាក់ការខ្ពស់ រស់បានយូរ! អូនឯង មើល! ឃើញ អ្ហេ?

បងស្រីះ លាក់ការខ្ពស់ រស់! បានយូរ។

កះចុះ លោកគ្រូ អ្ហឺ កាលហ្នឹង លាក់ការដែរ?

ខ៖លាក់ការ! ម្នាក់ហ្នឹង ទម្លក់ដៃ ក៏លាក់ការ លោកគ្រូ អ្ហឺ អ្ហឺ ក៏លាក់ការ! បាទ! ដើម្បីរស់ ដើម្បី អ្ហឺ ក្រពះ! បបរទឹក កាខ្លូក(បបររាវសុទ្ធតែទឹក) រួចគ្រាប់អង្ករ តែពីរ បីគ្រាប់ អ្ហេ! រួច អ្ហឺ រស់យ៉ាងម៉េច ទៅទៀត អ្ហឺ ប្អូន អ្ហើយ... រស់! យ៉ាងម៉េចទៀត?។ ណា! អំបិល មិនសូវ អ្ហឺ អោយហូបគ្រប់គ្រាន់ទេ! អំបិល! រួចហើមជើង ហើមដៃ ហើម!

ក៖ហើយចុះ ពេលហើមហ្នឹង លោកគ្រូ មានអី ព្យាបាលទៅលោកគ្រូ? ពេលហើមទៅ អ្ហឺ អ្ហឺ លោកគ្រូ ប្រាប់វាទៅ! ប្រាប់ទៅ អ្ហឺ វាយកទៅពេទ្យ ទៅ! រួច អ្ហឺ ទៅពេទ្យហ្នឹង អ្ហឺ វាមានអាចមិស្សាយ(ថ្នាំអាចមិទន្សាយ) រក អ្ហឺ... អាម្បែ! អាតាឡូង ឈើ... ហ្នឹង! រួច លេបតាំង ម៉ា! កាប៉ង់ ម៉ា! កាប៉ង់! ចេះតែលេបទៅ(ពេទ្យអោយលោកគ្រូ លេបថ្នាំ ច្រើនណាស់)

ក៖ហ៊ឹម... ចាស លោកគ្រូ ហើយបាត់ទៅ?

ខ៖អ្ហឺ លេបទៅ បាត់ទៅ បាត់ទៅ ហៅយើងទៅ ធ្វើការទៀត ហៅធើការ ទៀត។

ក៖ចាស រួច អ្ហឺ ដល់ អ្ហា ពេល អ្ហឺ ៧៩! ពេល អ្ហឺ ៧៩ ហ្នឹង! រំដោះ អ្ហឺ បាន អ្ហឺ ទីក្រុងភ្នំពេញ ហើយ! អ្ហឺ គរុកោសល្យខេត្ត ហ្នឹង! ពេទ្យហ្នឹង គេចុះ មូលដ្ឋានហ្នឹង ដែលអ្នក រស់ហ្នឹង ប៉ុន្មាន នាក់? អ្នកស្លាប់ហ្នឹង បានប៉ុន្មាននាក់? គេស្រាវជ្រាវ ហ្នឹង! នៅ អ្ហឺ ជំនាន់ អាពតហ្នឹង អូ?

ក៖ចាស

ខ៖ដល់ម៉ោ អ្ហា ឃើញខ្ញុំ ស្គម... ដើរចង់ដួលហើយ វាសួរខ្ញុំ ថា! អ្ហឺ បងឯង! បើ អ្ហឺ វាបក់ដៃ ហៅខ្ញុំម៉ោ រួច ពេទ្យហៅសួរខ្ញុំ ថា! បងឯង អ្ហឺ ម៉េចៗស្គម អើយ! ស្គមម៉េស? បាន ខ្ញុំថា៖ លោកគ្រូ ពេទ្យអើយ ខ្ញុំ ខ្ញុំ អ្ហឺ ស្គម ដោយសារ ខ្ញុំបាក់កំលាំង អ្ហឺ ជំនាន់អាពត វែកដី! អ៊្ហូស !

ក៖ហ៊ឹម...

ខ៖គ្រាន់តែគាត់ភ្លាត់ សំលេង ថា អ្ហឺ អ៊្ហូស ហ្នឹង! អ្ហឺ ដុកទ័រ អ្ហឺ ប៉ុន្មាននាក់ហ្នឹង អ្ហឺ ថាប៉ុន្មាននាក់ អ្ហឺ បានពិគ្រោះគ្នា ហ្នឹង! អ្ហឺ ថា៖ រួចទៅ បងឯង អ្ហឺ ពិសារ បាយបានអ្ហេ? បាទ! បាន អ្ហឺ លោកគ្រូ ពេទ្យ តែធើបាប ធើការ បាក់កំលាំង ហួសម៉ោង ហួសពេល អត់មាន អ្ហឺ ទឹកមុជទេ ថា! អ្ហឺ អាវសិត(សុទ្ធ) កាកអំបិល គ្រាន់! អ្ហា ពេទ្យ ហ្នឹង! ស្រែក អ៊្ហូស! អញ្ចឹង ម៉ា! សន្ទុក ហៅយើង ហៅ អ្ហឺ ឡើងលើគ្រែ អ្ហឺ ថា បងឯង ដោះអាវហើយ។ (លោកគ្រូលាន់មាត់)ចុយ ម៉ាយហើយ! ភ័យញ័រ អ្ហា ភ័យញ័រ អ្ហឺ ខ្លាចតែយើង ដោះអាវទៅ ល័! ល័! យកកាំបិតតាំងតោ អ្ហឺ វះពោះ យើងទៅ វានឹក ឃើញ អញ្ចេក! កាលនុង វាឆោតល្ងង់! អ្ហា(សើច)

បងស្រី៖ ចាស!(សើច)

ខ៖ដល់ អ្ហឺ យើងដេកស្ទូក ស្ទឹងទៅ អ្ហឺ អ្ហឺ ថាគេយក អាប្រដាប់ស្ទង់ នុះ! ជីបចរ បេះដូងយើង អ្ហឺ ស្ទូត ដង្ហើម ដកដង្ហើម នុះ! ពោះយើង ហ្នឹងអ្ហា...

បងស្រី៖ ចាស

ខ៖ពិនិត្យមើល អ្ហឺ រួចអស់ទៅ អ្ហឺ អោយយើងពាក់អាវវិញ អោយយើងពាក់អាវ វិញ! ទាល់នេះទៅ!(ពេទ្យនិយាយ) បងឯង កុំងើប! បងឯង នៅសំរានគ្រែ ហ្នឹងអ្ហា! កុំងើប រួច អ្ហេ អ្ហឺ អ្ហឺ អត់អោយងើប អញ្ចឹង! ឈប់ខ្ញុំវៃ ជួង! អោយគេសិន អ្ហឺ មានតែប៉ុហ្នឹង ទេ... តស្ស៊ូ អ្ហឺ រស់ ប៉ុហ្នឹង ប៉ុហ្នឹង! ។

ក៖ចាស លោកគ្រូ ចាស! លោកគ្រូ អ្ហឺ...

ខ៖បាទ

ក៖ លោកគ្រូ អ្ហឺ ជាចុងក្រោយ តើលោកគ្រូ អ្ហឺ មានពាក្យពេចន៍អី ដែលចង់ផ្ដែផ្ដាំ ដល់កូនចៅជំនាន់ក្រោយ ដែលចូលស្ដាប់ អ្ហឺ សំលេង ហ្នឹង! និង ពាក្យពេចន៍ លោកគ្រូ នៅថ្ងៃនេះអ្ហា?

ខ៖អ្ហឺ ខ្ញុំផ្ដែផ្ដាំ មានតា(មានតែ) អ្ហឺ កុំអោយ វេទនា អ្ហឺ ដូចខ្ញុំ! អ្ហាណា។ ខ្ញុំ អ្ហឺ វាហាក់លោត វេទនាឆ្លងកាត់ អស់ប៉ុហ្នឹងហើយ កុំអោយ កុំអោយ អ្ហឺ មានជួបប្រទះ មាន អ្ហឺ បញ្ហា អញ្ចឹង!អ្ហា ទី១ អ្ហឺ កុំអោយ អ្ហឺ បែកបាក់ ឪពុកម្ដាយ ព្រាត់ប្រាស កូន! អ្ហឺ អញ្ចឹងអ្ហា! ហើយ អោយជុំគ្នា ស្រលាញ់គ្នា អ្ហាណា! ទៅវិញ ទៅម៉ោ! ហ្នឹងអ្ហា ហើយ! អ្ហឺ ទី២ កុំអោយ អ្ហឺ ជួបនូវរបប យោយៅព្រៃផ្សៃ ហ្នឹង! កុំអោយ មានអោយសោះ និង អ្ហឺ ឆាកជីវិតយើង កុំអោយជួបបញ្ហា ចឹង! ចឹងអ្ហា! បញ្ហាហ្នឹង មិនស្រួលទេ ទាល់ អ្ហា ចាស់ទៅ យើងឈឺស្កាត់(ថ្កាត់)អ្ហា វា អ្ហឺ អត់មានអ្នកណា មើលយើងអ្ហា ថៃទាំយើង... ណា! ចឹងបាន អ្ហាថា ណា! លោកគ្រូ អ្ហឺ ផ្ដាំផ្ញើតែប៉ុហ្នឹង អ្ហឺ ទេ! មានអីច្រើន ទេ!

បងស្រី៖ រួចលោកគ្រូ ដល់ពេល ឈឺ ដល់ពេលអី ណាគេ មើល ទៅ?

ខ៖មានតែបងប្អូន ជីដូនមួយហ្នឹង មើលអ្ហា ហើយ! ណា...

បងស្រី៖ហ៊ឹម...

ខ៖ណា! វា អ្ហឺ ធ្លាប់ដឹងដែរ វាដឹងថា យើងមិនមែន អ្នកក្រៅ អឺណា! យើងជាប់សាច់ឈាមរវាងបងប្អូន រវាងបងប្អូន ជីដូនមួយហ្នឹង

បងស្រី៖លោកគ្រូ ខាងណា ខាងណា?

ខ៖ខាង ម្ដាយមីង!

បងស្រី៖ខាងម្ដាយ?

ខ៖បាទ ខាងម្ដាយមីង រួចម្ដាយមីង អ្ហឺ ម្ដាយមីង! ពីព្រោះ ខាងម្ដាយ និងម្ដាយមីង អ្ហឺ បងប្អូនបង្កើត

ក៖ចាស ចាស អាល្ងូវ...

ខ៖បាទ

ក៖ចុះលោកគ្រូ អ្ហឺ មានពាក្យពេចន៍អី បន្ថែមទៀត អត់លោកគ្រូ?

ខ៖អត់មានពាក្យពេចន៍អី បន្ថែម! ទេ... មានតែផ្ដាំផ្ញើ ហ្នឹង! ថា... បើរៀបការ គិតតែទៅមុខ កុំងាកក្រោយ អោយសោះ កុំជឿសំដីគេ អ្នកក្រៅ គេចាក់រុក ឆ្កើសឆ្កៀល អោយសោះ ទៅមុខ អ្ហឺ វា អ្ហឺ ត្រូវតែ ទៅមុខ! កុំជឿគេ មានតែទៅមុខ មានតែប៉ុហ្នឹង អ្ហឺ ទេ!(សើច) ព្រោះឆ្លងកាត់យើង អ្ហឺ ជួបប្រទះ អញ្ចឹង! អ្ហា ទៅហើយ(សើច)

ក៖អញ្ចឹង! អរគុណលោកគ្រូ អ្ហឺ ច្រើន អ្ហឺ សំរាប់ថ្ងៃនេះ ដែលបាន ចំណាយពេល នៅថ្ងៃនេះច្រើន ដែលក្នុងការសម្ភាស អ្ហា អ្ហឺ លោកគ្រូ

ខ៖បាទ

ក៖អញ្ចឹង លោកគ្រូ អ្ហឺ បើខាងសាលារៀន BYU នៅសហរដ្ឋ អ្ហឺ នៅអាមេរិក អ្ហឺ ដែលគេ ចង់ដាក់សំលេងលោកគ្រូដែលគេ ចង់ដាក់សំលេងលោកគ្រូ ដែលមានគេហទំព័រដែលមានអាស័យដ្ឋាន www.cambodianoralhistory.byu.edu អ្ហឺ ដើម្បីទុកអោយ អ្ហឺ កូនចៅជំនាន់ក្រោយ ទៀត អ្ហឺ អ្ហឺ បានមានឪកាស អ្ហឺ ចូលទៅស្ដាប់សំលេង អ្ហឺ នូវពាក្យពេចន៍ លោកគ្រូ! អ្ហឺ ថ្ងៃនេះផង ...

ខ៖បាទ

ក៖អ្ហឺ នឹងថតរូប លោកគ្រូ ម៉ាសន្លឹក ដើម្បី អ្ហឺ ទុក អ្ហឺ ជាមួយនឹងសំលេង នៅថ្ងៃនេះ! លោកគ្រូអនុញ្ញាតិ អ្ហេ! តា (សុំគាត់អនុញ្ញាតិ ដាក់សំលេងគាត់ដាក់ក្នុងវេបសាយ) អ្ហឺ លោកគ្រូ?

ខ៖បាទ(សើច)

ក៖(សើច)

ខ៖ ខ្ញុំ ខ្ញុំអត់ចេះយាយ(និយាយ)ថា(សើច)! ចេះ អ្ហឺ តែយាយៗ(និយាយ)ទៅ! ចេះតែប៉ុហ្នឹង អ្ហា តា... យាយ(និយាយ) ថា...

ក៖ហ្នឹងហើយ

ខ៖បាទ

ក៖ចាស លោកគ្រូ ហ្នឹងហើយ! អញ្ចឹង! អ្ហឺ លោកគ្រូ បើខាងសាលា អ្ហឺ បើគេចង់ដាក់លោកគ្រូក្នុងទំព័រមួយហ្នឹង លោកគ្រូ នឹងអនុញ្ញាតិដែរ តា! លោកគ្រូ អ្ហឺ ណ្ណា?

ខ៖បាទ អនុញ្ញាតិ អ្ហា បាន! បាទៗ

ក៖អរគុណច្រើន អ្ហា លោកគ្រូ។

ខ៖បាទៗ